

អង្គការ ជីវិតនៅកម្ពុជា
THIS LIFE CAMBODIA

# ការរៀនគួ និងការរៀននៅសាលារដ្ឋ
# ការសិក្សាស្រាវជ្រាវលើសាលាចំនួន៦ នៃប្រទេសកម្ពុជា

រក្សាសិទ្ធិ© ដោយអង្គការជីវិតនៅកម្ពុជា ខែមីនា ឆ្នាំ២០១២

នេះជារបាយការណ៍ផ្លូវការរបស់អង្គការជីវិតនៅកម្ពុជា។ របាយការណ៍នេះ ត្រូវបានសរសេរដោយ លោក ទូត ម.ន និងលោក វីលៀម ស៊ី ប្រិម។ សូមអរគុណជាពិសេសចំពោះលោក សែន សែ លោក ហ៊ុល រិទ្ធាវី និងកញ្ញា ជា ប៊ូរ៉ានីដែលបានជួយធ្វើការកែសម្រួល។

ពាល់ការផលិតឡើងវិញនូវរបាយការណ៍នេះ ដោយមានការបញ្ជាក់ច្បាស់លាស់អំពីប្រភព សម្រាប់គោលបំណងដែលមិនរកប្រាក់ចំណូល ត្រូវបានអនុញ្ញាត។

ចំពោះការថតចម្លង (ដោយផ្លាស់ប្តូរទ្រង់ទ្រាយដើម) នៅគ្រប់កាលៈទេសៈទាំងអស់ ឬការប្រើប្រាស់ឡើងវិញក្នុងការបោះពុម្ពផ្សេងទៀត ឬការបកប្រែ ឬការកែសម្រួលយកមកប្រើប្រាស់ ត្រូវប្រឹក្សាជាមួយអង្គការជីវិតនៅកម្ពុជា។

សម្រាប់ព័ត៌មានបន្ថែមស្តីពីបញ្ហា ដែលបានលើកឡើងក្នុងរបាយការណ៍នេះ សូមទាក់ទង អង្គការជីវិតនៅកម្ពុជា។ ព័ត៌មាននៅក្នុងរបាយការណ៍នេះ ត្រឹមត្រូវនៅក្នុងអំឡុងពេលនៃការបោះពុម្ពផ្សាយ។

ឧបត្ថម្ភដោយៈ OPEN SOCIETY INSTITUTE(OSI) ដែលមានការចូលរួមពីកម្មវិធីគាំទ្រការអប់រំ របស់ OSI BUDAPEST

បោះពុម្ពដោយ

អង្គការជីវិតនៅកម្ពុជា ផ្ទះលេខ ៣១៣ ក្រុមទី៩ ភូមិសាលាកន្សែង ឃុំស្វាយដង្គំ សៀមរាប ព្រះរាជាណាចក្រកម្ពុជា

ប្រអប់សំបុត្រលេខ ៩៣១៩០ សៀមរាបអង្គរ ព្រះរាជាណាចក្រកម្ពុជា

អាសយដ្ឋានអេឡិចត្រូនិក: contact@thislifecambodia.org www.thislifecambodia.org

# សេចក្តីផ្តើម

ការសិក្សានៅលើពិភពលោកយើងនេះ ត្រូវតែមានការចំណាយដោយនរណាម្នាក់។ ការអប់រំត្រូវចំណាយថវិកាច្រើន។ ជាទូទៅ ប្រទេសកំពុងអភិវឌ្ឍន៍ ពុំអាចលៃលកថវិកាឲ្យគ្រប់គ្រាន់ សម្រាប់ចំណាយទៅលើការអប់រំទេ។ ហេតុដូច្នេះហើយការចំណាយមួយចំនួនលើការអប់រំត្រូវធ្លាក់ទៅលើក្រុមគ្រួសារសិស្ស។

ដូចគ្នាដែរ នៅក្នុងប្រទេសកម្ពុជា ក្រុមគ្រួសារសិស្សក៏បានចូលរួមចំណែក ជាមួយរាជរដ្ឋាភិបាល ក្នុងការចំណាយលើការអប់រំរបស់កូនៗគាត់ដែរ។ តាមរយៈសាលារៀនដែលយើងធ្វើការជាមួយ យើងបានដឹងថាមានការចំណាយច្រើនរបស់ក្រុមគ្រួសារលើការអប់រំរបស់កូនគាត់ ជាពិសេសលើការរៀនគួ។ ការបង្កើនចំណេះដឹង ដើម្បីបង្គ្រប់បន្ថែមនូវអ្វីដែលបានសិក្សានៅក្នុងថ្នាក់រៀនរដ្ឋ ជាចំណុចវិជ្ជមានមួយដែលការរៀនគួបានផ្តល់ឲ្យប៉ុន្តែការរៀនគួត្រូវការចំណាយថវិកាទៅគ្រូបង្រៀន ដើម្បីបន្ថែមលើប្រាក់ខែរបស់ពួកគាត់។ មានតែសិស្សមួយចំនួនប៉ុណ្ណោះ ដែលបានទៅរៀនគួ ដោយសារក្រុមគ្រួសារពួកគេមានលទ្ធភាពបង់ថ្លៃរៀនគួ។ រីឯសិស្សមួយចំនួនទៀតដែលគ្រួសារមិនមានលទ្ធភាពនោះ មិនអាចទៅរៀនគួបានឡើយ (បើទោះបីមានគ្រូបង្រៀនខ្លះមិនយកលុយពីសិស្សក្រីក្រក៏ដោយ)។ បញ្ហានេះហើយ ធ្វើឲ្យការទទួលបានការអប់រំ មានលក្ខណៈមិនស្មើគ្នា។ ម្យ៉ាងទៀតនាពេលបច្ចុប្បន្ននេះកំពុងតែមានការកើនឡើង នៃការឲ្យតម្លៃលើការរៀនគួច្រើនជាងការរៀននៅសាលារដ្ឋ ទាំងផ្នែកចំណេះដឹង (សម្រាប់សិស្ស) និងការរកប្រាក់ចំណូល (សម្រាប់គ្រូ)។ ហេតុដូច្នេះហើយ បានជាយើងធ្វើការសិក្សាស្រាវជ្រាវនេះឡើង ដើម្បីឲ្យបានយល់ដឹងកាន់តែស៊ីជម្រៅអំពីបញ្ហាសង្គម ដែលបណ្តាលមកពីការជ្រៀតចូលនូវប្រព័ន្ធអប់រំឯកជន (រៀនគួ) ទៅក្នុងប្រព័ន្ធអប់រំរបស់រដ្ឋ។

ការសិក្សាស្រាវជ្រាវនេះ ឆ្លើយតបនឹងសំណួរចំនួនបីគឺ៖

១. តើកត្តាអ្វីខ្លះដែលជម្រុញឲ្យមានការរៀនគួកើតឡើង ?

២. តើការរៀនគួ ជះឥទ្ធិពលអ្វីខ្លះដល់ការសិក្សានៅសាលារដ្ឋ ?

-តើមានភាពខុសគ្នា ដូចម្តេចខ្លះក្នុងការប្រើប្រាស់វិធីសាស្រ្ត បង្រៀននៅក្នុង ថ្នាក់រដ្ឋ និងថ្នាក់រៀនគួ ?

- តើការរៀនគួជះឥទ្ធិពលអ្វីខ្លះដល់ជម្រើសរបស់គ្រួសារ លើការផ្តល់សេវាអប់រំរដ្ឋ និងឯកជន ?

៣. តើមានផលវិបាកអ្វីខ្លះ ដោយសារការរៀនគួ ចំពោះសមធម៌សង្គម និងសេដ្ឋកិច្ចរយៈពេលវែង ?

## រំលឹកទ្រឹស្តី

ការរៀនគួមិនមានតែនៅក្នុងប្រទេសកម្ពុជាទេ វាកើតឡើងនៅក្នុងប្រទេសជាច្រើននៅក្នុងពិភពលោកដូចជាប្រទេសក្នុងសហគមន៍អឺរ៉ុប (Bray, 2011: 21-23) ប្រទេសអេស៊ីប (Fergany, 1994 ដកស្រង់ដោយ Bray, 2003: 22) ឥណ្ឌា (Aggarwal, 1998 ដកស្រង់ដោយ Bray, 2003: 23) ប្រទេសកេនយ៉ា (Nzomo et al., 2001 ដកស្រង់ដោយ Bray, 2003: 23)ប្រទេសគុយវ៉ែត (Hussein, 1987: 92 ដកស្រង់ដោយ Bray, 2003: 31) និងស្រីលង្កា (Nanayakkara & Ranaweera, 1994: 14 ដកស្រង់ដោយ Bray, 2007: 52)។ ប៉ុន្តែទម្រង់នៃការរៀនគួនៅក្នុងប្រទេសនីមួយៗមិនដូចគ្នាទាំងអស់នោះទេ។

អ្នកស្រាវជ្រាវបានរកឃើញនូវមូលហេតុផ្សេងៗដែលធ្វើឲ្យមានការរៀនគួកើតឡើង ដែលមូលហេតុទាំងនោះទាក់ទងនឹងតម្រូវការ និងការផ្គត់ផ្គង់នៃការរៀនគួ។ លោក ម៉ាក ប្រេ (2011: 33-38) បានបង្ហាញនូវមូលហេតុចម្បង៣យ៉ាងខាងផ្នែកតម្រូវការ គឺទី១មានការប្រលងប្រជែងច្រើន ទី២កម្មវិធីសិក្សាច្រើនពេកនិងទី៣កត្តាជំរុញពីឪពុកម្តាយ និងមិត្តភក្តិ។ ការកើនឡើងនៃការរៀនគួក៏បណ្តាលមកពីផ្នែកផ្គត់ផ្គង់ផងដែរ ដូចជាប្រាក់ខែគ្រូបង្រៀនទាប និងគុណភាពមិនសូវល្អនៃប្រព័ន្ធអប់រំរដ្ឋជាដើម (Hallak និង Poisson, 2007: 265-266)។

លោក ម៉ាក ប្រេ (2009:13) បានហៅការរៀនគួ ជាការអប់រំបែបស្រមោល (shadow education) ដោយសារមូលហេតុ៤យ៉ាង។ទី១ការរៀនគួកើតឡើងដោយសារមានការ សិក្សានៅសាលារដ្ឋ (mainstream education system)។ ប្រសិនបើមិនមានការសិក្សានៅសាលារដ្ឋទេនោះ ប្រហែលជាមិនមានការរៀនគួទេ។ ទី២នៅពេលទំហំ និងរូបរាងនៃការសិក្សានៅសាលារដ្ឋប្រែប្រួល ទំហំ និងរូបរាងនៃការរៀនគួក៏មានការប្រែប្រួលដែរ។ ឧទាហរណ៍៖ ប្រសិនបើមានការកើនឡើងថ្នាក់នៃការប្រលងថ្នាក់ជាតិ នោះការរៀនគួទំនងជានឹងមានការកើនឡើងដែរ ហើយប្រសិនបើចំនួនម៉ោងសិក្សានៅក្នុងថ្នាក់រដ្ឋមានការកើនឡើង នោះការរៀនគួអាចនឹងថយចុះ។ ទី៣ស្ទើរតែនៅគ្រប់ទីកន្លែងទាំងអស់ ស្រមោលមិនត្រូវបានចាប់អារម្មណ៍ដូចវត្ថុពិតរបស់វាទេ មានន័យថាប្រសិនបើយើងលើកយកពាក្យថាប្រព័ន្ធអប់រំមកជជែកគ្នានោះ មនុស្សភាគច្រើនទំនងជានឹងលើកយកការសិក្សានៅសាលារដ្ឋ ឬសាលាឯកជនមួយចំនួនមកនិយាយតែប៉ុណ្ណោះ ដោយពុំបាននិយាយអំពីការរៀនគួ



ដែលកើតឡើងនៅក្រៅប្រព័ន្ធអប់រំរដ្ឋ និង
ដែលជាផ្នែកមួយនៃការអប់រំដែរនោះទេ។ ទី៤
ប្រព័ន្ធអប់រំបែបស្រមោលមានលក្ខណៈមិន
ច្បាស់លាស់ មិនមានការកំណត់ដូចនៅក្នុង
ប្រព័ន្ធអប់រំរដ្ឋទេ។ យើងដឹងហើយថា
”ស្រមោល” មានលក្ខណៈមិនច្បាស់ដូច
”របស់ពិត” នោះទេ។ ត្រង់ចំណុចនេះយើង
ចាត់ទុកការរៀនគួប្រៀបបានដូចជា
ស្រមោលមានន័យថាមិនមានការដាក់
កម្រិតច្បាស់លាស់ ទៅលើការរៀនគួដូចនៅ
ការសិក្សានៅសាលារដ្ឋទេ។ ការរៀនគួអាច
កើតឡើងនៅគ្រប់ទីកន្លែង (ដូចជាផ្ទះរបស់គ្រូ
ផ្ទះរបស់សិស្ស ខ្លះទៀតនៅក្នុងបរិវេណ
សាលារដ្ឋ។ល។) គ្រូអាចបង្រៀនអ្វីដោយមិន
មានការកំណត់ពីក្រសួងអប់រំ យុវជននិងកីឡា
(តទៅពាក្យ ”ក្រសួង” នឹងត្រូវប្រើជំនួសពាក្យ
”ក្រសួងអប់រំ យុវជន និងកីឡា”) សិស្សមិន
ចាំបាច់ស្លៀកពាក់ឯកសណ្ឋាន ឬអង្គុយនៅ
កន្លែងណាឲ្យពិតប្រាកដនៅក្នុងថ្នាក់រៀនគួ
នោះទេ។ ចំណែកឯនៅក្នុងប្រព័ន្ធអប់រំរដ្ឋវិញ
ការសិក្សាត្រូវតែកើតឡើងនៅសាលារដ្ឋ
សិស្សត្រូវតែស្លៀកពាក់ឯកសណ្ឋាន ហើយ
គ្រូត្រូវបង្រៀនទៅតាមកម្មវិធីសិក្សារបស់
ក្រសួង។

ជាក់ស្តែង នៅក្នុងប្រទេសកម្ពុជា ការ
អប់រំមិនកើតឡើងតែនៅក្នុងសាលារដ្ឋនិង
ម៉ោងសិក្សារបស់រដ្ឋនោះទេ យើងសង្កេត
ឃើញសកម្មភាពនៃការអប់រំកើតឡើងជា
រៀងរាល់ថ្ងៃ សូម្បីតែនៅថ្ងៃចុងសប្តាហ៍។
សិស្សអាចទទួលការអប់រំផ្សេងៗគ្នា
ទៅតាមការជ្រើសរើសរបស់ពួកគេតាម រយៈ
ការសិក្សាជាលក្ខណៈឯកជន ដែល នៅក្នុង
នោះមានការរៀនគួផងដែរ។ ការរៀនគួនៅ
ក្នុងប្រទេសកម្ពុជា កើតឡើងក្រោមរូបភាព
ជាច្រើន ដូចជាមានការរៀនគួពិសេស(extra
special private tutroing) ការរៀនគួធម្មតា
(normal private tutoring)
ការរៀនគួនៅតាមសាលាឯកជន (elective
private tutoring)ការរៀនគួសម្រាប់ការប្រលង
(test preparation private tutoring)
ការរៀនគួពេលវិស្សមកាល (summer private
tutoring) និងការរៀនគួជាមួយគ្រូដែលមិន
បានបង្រៀនខ្លួននៅថ្នាក់រដ្ឋដើម្បីធ្វើឲ្យប្រសើរ
ឡើងនូវចំណុចខ្វះខាត (remedial private
tutoring)។

ការរៀនគួពិសេស (extra special
private tutoring) ជាទូទៅកើត ឡើង នៅផ្ទះ
របស់គ្រូ ឬផ្ទះរបស់សិស្សផ្ទាល់ ដែលនៅក្នុង
ថ្នាក់គួនេះគ្រូបង្រៀនម្នាក់បង្រៀនសិស្សម្នាក់

ឬសិស្សមួយក្រុមតូចដោយសិស្សត្រូវបង់ថ្លៃច្រើនជាងការរៀនគួធម្មតា។

នៅក្នុងការរៀនគួធម្មតា (normal private tutoring) គឺសិស្សភាគច្រើនមកពីសាលារដ្ឋទៅរៀនជាមួយគ្រូដែលបង្រៀនពួកគេនៅក្នុងថ្នាក់រដ្ឋ។ ការរៀនគួធម្មតានេះកើតឡើងក្រៅម៉ោងរដ្ឋ ដោយខ្លះកើតឡើងក្នុងបរិវេណសាលារដ្ឋ ខ្លះទៀតកើតឡើងក្រៅបរិវេណសាលាដូចជានៅផ្ទះរបស់គ្រូបង្រៀនជាដើម។

សម្រាប់ការរៀនគួនៅតាមសាលាឯកជន (elective private tutoring) សិស្សអាចជ្រើសរើសមុខវិជ្ជាដែលមិនមានរៀនក្នុងសាលារដ្ឋនៅតាមវិទ្យាស្ថានឬសាលាឯកជននានាដូចជាភាសាបរទេស កុំព្យូទ័រជាដើម(សម្រាប់សិស្សបឋមសិក្សា)កីឡានិងតន្ត្រី។ ជាទូទៅគ្រូបង្រៀននៅសាលាឯកជននេះមិនមែនជាគ្រូបង្រៀនរបស់សិស្សដែលនៅសាលារដ្ឋនោះទេ។

រីឯការរៀនគួសម្រាប់ការប្រលង (test preparation private tutoring) មានសិស្សយ៉ាងច្រើនជួបជុំគ្នា ដើម្បីរៀនគួត្រៀមប្រលងថ្នាក់ជាតិ និងដើម្បីត្រៀមប្រលងចូលមហាវិទ្យាល័យនានានៅក្នុងសាកលវិទ្យាល័យរដ្ឋ។ គ្រូបង្រៀនជាច្រើននៅសាលារដ្ឋបានប្រមូលផ្តុំគ្នានៅទីកន្លែងមួយ(អាចបើកជាសាលាឯកជន) ដើម្បីបង្រៀនគួសម្រាប់ការត្រៀមប្រលងទាំងនេះ។ មុខវិជ្ជាដែលត្រូវការរៀនគួមាននៅទីនោះទាំងអស់ ដែលធ្វើឲ្យមានភាពងាយស្រួលដល់សិស្សក្នុងការជ្រើសរើស និងធ្វើឲ្យមានសិស្សយ៉ាងច្រើនប្រមូលផ្តុំគ្នានៅទីនោះ។

ការរៀនគួពេលវិស្សមកាល (summer vacation private tutoring) កើតឡើងនៅពេលឆ្នាំសិក្សាបញ្ចប់ ដែលសិស្សត្រូវបានតម្រូវឲ្យឈប់សម្រាកពីការសិក្សានៅសាលារដ្ឋ មុននឹងចាប់ផ្តើមឆ្នាំសិក្សាថ្មី។ នៅចន្លោះពេលនេះយើងសង្កេតឃើញថាសិស្សមួយចំនួននៅតែបន្តការសិក្សារបស់ពួកគេ នៅថ្នាក់រៀនគួជាមួយនឹងអនាគតគ្រូនៅឆ្នាំសិក្សាថ្មីរបស់ពួកគេ ឬជាមួយនឹងគ្រូដែលបង្រៀនពួកគេនៅឆ្នាំសិក្សាចាស់។ នៅថ្នាក់រៀនគួនេះយើងមិនបានដឹងច្បាស់ថា សិស្សបន្តសិក្សាកម្មវិធីសិក្សាថ្នាក់ចាស់ ឬកម្មវិធីសម្រាប់ថ្នាក់បន្ទាប់ដែលពួកគេនឹងសិក្សានៅឆ្នាំសិក្សាថ្មីនោះទេ។

ការរៀនគួដើម្បីធ្វើឲ្យប្រសើរឡើងនូវមុខវិជ្ជាឬចំណុចណាមួយដែលសិស្សរៀនខ្សោយ (Remedial private tutoring) ដោយការបង្រៀនអាចធ្វើឡើងដោយនរណាក៏បានដែលមានសមត្ថភាពជួយ ដូចជាមិត្តភក្តិបងប្អូន ឬអាចនៅកន្លែងដែលមានផ្តល់សេវាបែបនេះ។ គ្រួសារសិស្សមិនចាំបាច់ត្រូវតែចំណាយលើការរៀនគួប្រភេទនេះទេ។

នៅក្នុងការសិក្សាស្រាវជ្រាវនេះ យើងមិនបានសិក្សាទៅលើការរៀនគួគ្រប់ទម្រង់ទាំងអស់នោះទេ គឺយើងសិក្សាតែលើការរៀនគួធម្មតានៅក្នុងប្រព័ន្ធអប់រំសាលារដ្ឋតែប៉ុណ្ណោះ ដោយផ្តោតសំខាន់ទៅលើកម្មវិធីសិក្សានិងកត្តាសង្គម។

នៅក្នុងប្រទេសកម្ពុជា ក្នុងទស្សវត្សរ៍ឆ្នាំ១៩៩០ ការអង្កេតទៅលើសិស្សថ្នាក់ទី៦ នៅសាលាចំនួន ៧៧ បានបង្ហាញថា សិស្សថ្នាក់ទី ៦ ជាង ៣០ % បានទៅរៀនគួដែលជាទូទៅបង្រៀនដោយគ្រូនៅសាលារដ្ឋរបស់ពួកគេ (Bray, 1999: 57)។

## វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ផ្អែកលើទិន្នន័យដែលបានមកពីការចុះសង្កេតនៅតាមថ្នាក់រៀនគួ និងតាមថ្នាក់រៀនរដ្ឋការពិភាក្សាក្រុមជាមួយគ្រូបង្រៀន សិស្ស និងមាតាបិតាសិស្ស និងការប្រៀបធៀបលទ្ធផលនៃការសិក្សារបស់សិស្សដែលរៀនគួនិងសិស្សដែលមិនបានរៀនគួ។

### ១. ការចុះសង្កេត

នៅក្នុងការប្រមូលទិន្នន័យតាមរយៈការចុះសង្កេតនៅតាមថ្នាក់រៀនគួ និងតាមថ្នាក់រៀននៅសាលារដ្ឋ យើងបានប្រើប្រាស់បញ្ជីផ្ទៀងផ្ទាត់(checklist) ដែលបានមកពីរបាយការណ៍មួយរបស់ធនាគារពិភពលោក (Benveniste, et al., 2008, pp. 89-91)។ បញ្ជីផ្ទៀងផ្ទាត់នេះផ្តោតសំខាន់ទៅលើវិធីសាស្ត្របង្រៀន សកម្មភាពនៅក្នុងថ្នាក់រៀន (classroom characteristics) និងការប្រើប្រាស់ពេលវេលាទៅលើសកម្មភាពផ្សេងៗ ក្នុងពេលរៀន និងបង្រៀន។

ក្រោយពីបានប្រមូលទិន្នន័យអំពីតម្លៃរៀនគួនៅគ្រប់អនុវិទ្យាល័យទាំងអស់ (ចំនួន១៣) នៅក្នុងស្រុកមួយរួចមក យើង



បានជ្រើសរើសយកអនុវិទ្យាល័យចំនួន២ដែលមួយមានតម្លៃរៀនគួខ្ពស់បំផុត (១០០០រៀលឬប្រហែល០.២៥ដុល្លារអាម៉េរិក) និងមួយទៀតមានតម្លៃរៀនគួទាបបំផុត (៥០០រៀលឬប្រហែល០.១៣ដុល្លារអាម៉េរិក)។ អនុវិទ្យាល័យទាំងពីរនេះស្ថិតនៅក្នុងក្រុងមួយ និងនៅទីជនបទមួយ[1] ។ បន្ទាប់មកយើងជ្រើសរើសសាលាបឋមសិក្សាចំនួន៤ ដែលពីរមានទីតាំងភូមិសាស្ត្រជិតអនុវិទ្យាល័យមួយខាងលើ និងពីរទៀតនៅជិតអនុវិទ្យាល័យមួយទៀត។

នៅកម្រិតបឋមសិក្សា យើងចុះសង្កេតថ្នាក់ទី៦ និងអនុវិទ្យាល័យយើងចុះសង្កេតថ្នាក់ទី៩ លើមុខវិជ្ជាគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា និងភាសាខ្មែរ។ មុខវិជ្ជាទាំងនេះត្រូវបានជ្រើសរើសមកធ្វើការសង្កេតដោយសារបទពិសោធន៍ផ្ទាល់របស់អ្នកស្រាវជ្រាវដែលធ្លាប់ដឹង និងឆ្លងកាត់ការរៀនគួលើមុខវិជ្ជាទាំងនេះហើយក៏មានការលើកឡើងផងដែរថា មុខវិជ្ជាទាំងនេះជាមុខវិជ្ជាដែលពេញនិយមបំផុតសម្រាប់ការបង្រៀនគួនៅកម្រិតមធ្យមសិក្សាបឋមភូមិ (ម៉ាក ប្រេ & សេង ប៊ុនលី, ២០០៥, p. ៩១)។ ការជ្រើសរើសយកថ្នាក់ទី៦មកសិក្សាស្រាវជ្រាវ ដោយសារថ្នាក់ទី៦ជាថ្នាក់ដែលខ្ពស់ជាងគេនៅក្នុងកម្រិតបឋមសិក្សាដែលសិស្សអាចមានសមត្ថភាពគ្រប់គ្រាន់សម្រាប់ការចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះ។

ចំណែកឯថ្នាក់ទី៩វិញ ជាថ្នាក់ដែលមានការ ប្រលងថ្នាក់ជាតិដើម្បីឆ្លងទៅកាន់ភូមិសិក្សាមួយទៀត (កម្រិតមធ្យមសិក្សាទុតិយភូមិ) ហើយដែលមានការរៀនគួច្រើនទៀតផង។ ម៉្យាង ទៀតទិន្នន័យមួយចំនួននៃថ្នាក់ទី៦ និងទី៩ដែលបានពីការស្រាវជ្រាវនេះអាចនឹងត្រូវបានប្រើប្រាស់សម្រាប់ធ្វើការប្រៀបធៀបទៅនឹងទិន្នន័យនៃការស្រាវជ្រាវនាពេលមុនៗ។

យើងបានចុះធ្វើការសង្កេតបានចំនួន២៨ដង ដែលនៅក្នុងនោះធ្វើនៅថ្នាក់រៀនគួចំនួន១៤ដង និងនៅថ្នាក់រដ្ឋចំនួន១៤ដងដែរ (សូមមើលតារាង១)។

នៅក្នុងការចុះសង្កេតទាំង២៨ដងនេះ មានការ ចុះសង្កេតចំនួន១៥ដងដែលយើងបានប្រើតែបញ្ជីផ្ទៀងផ្ទាត់ និង១៣ដងទៀតប្រើទាំងបញ្ជីផ្ទៀងផ្ទាត់ និងកត់ត្រារយៈពេលនៃសកម្មភាពនីមួយៗរបស់គ្រូបង្រៀនអំឡុងពេលសង្កេត។

[1] សាលាទាំងពីរនេះ ស្ថិតនៅក្នុងស្រុក/ក្រុងតែមួយ។ ទោះបីយើងគួរតែប្រើពាក្យថាក្រុង និងជាយក្រុងក៏ដោយ នៅក្នុងរបាយការណ៍នេះ យើងប្រើពាក្យក្រុង និងជនបទ ដើម្បីបែងចែកទីតាំងអនុវិទ្យាល័យទាំងពីរ ដោយសារអនុវិទ្យាល័យមួយ \ស្ថិតនៅចំទីរួមស្រុកក្រុងដែលប្រជាជនភាគច្រើនមានផ្ទះថ្ម មធ្យោបាយធ្វើដំណើរទំនើប (ឡាន ម៉ូតូថ្មីៗ) និងមិនពឹងផ្អែកលើការធ្វើកសិកម្ម។ រីឯអនុវិទ្យាល័យមួយទៀតស្ថិតនៅជាយស្រុក/ក្រុង ដែលប្រជាជនភាគច្រើនមានផ្ទះឈើ/ស្លឹក ប្រើកង់ជាមធ្យោបាយធ្វើដំណើរ និងមុខរបរពឹងផ្អែកលើការធ្វើកសិកម្ម។

**តារាង១៖ ចំនួននៃការសង្កេតតាមមុខវិជ្ជា និងកម្រិត**

| កម្រិត | មុខវិជ្ជា | ចំនួននៃការចុះសង្កេត | | |
|---|---|---|---|---|
| | | ថ្នាក់រដ្ឋ | ថ្នាក់រៀនគូ | សរុប |
| **ថ្នាក់ទី៥** | ភាសាខ្មែរ | ៣ | ២ | ៥ |
| | គណិតវិទ្យា | ១ | ២ | ៣ |
| | រូបវិទ្យា | ២ | ៣ | ៥ |
| | គីមីវិទ្យា | ០ | ៤ | ៣ |
| **ថ្នាក់ទី៦** | | ៨ | ៣ | ១១ |
| **សរុប** | | **១៤** | **១៤** | **២៨** |

## ២. ការធ្វើក្រុមពិភាក្សា

យើងបានធ្វើការប្រមូលទិន្នន័យតាមរយៈកាពធ្វើក្រុមពិភាក្សាជាមួយសិស្សដែលរៀនគូ សិស្សដែលមិនរៀនគូ គ្រូដែលបង្រៀនគូ គ្រូដែលមិនបង្រៀនគូមាតាបិតាសិស្សដែលរៀនគូ និងមាតាបិតាសិស្សដែលមិនរៀនគូ ដោយប្រើប្រាស់ទម្រង់បញ្ជីសំណួរផ្សេងៗគ្នាដែលយើងបានរៀបចំកត់ត្រាការពិភាក្សា និងប្រើឧបករណ៍ថតសម្លេងដើម្បីផ្ទៀងផ្ទាត់ទិន្នន័យឡើងវិញ។

នៅក្នុងការរៀបចំក្រុមពិភាក្សាជាមួយសិស្សយើងបានទាក់ទងជាមួយនាយកសាលា ឬគ្រូបង្រៀនរបស់ពួកគេដោយផ្ទាល់ និងតាមទូរស័ព្ទដើម្បីឲ្យពួកគាត់ជួយសម្រួលដល់ការធ្វើការពិភាក្សាក្រុម។ ចំណែកឯការរៀបចំការពិភាក្សាក្រុមជាមួយគ្រូបង្រៀនវិញ យើងបានទាក់ទងទៅពួកគាត់ផ្ទាល់ ឬខ្លះតាមរយៈនាយកសាលា ឲ្យគាត់ជួយសម្រួលដល់ការងារនេះ។

សម្រាប់ការរៀបចំការពិភាក្សាក្រុមជាមួយមាតាបិតាសិស្សវិញ យើងបានទូរស័ព្ទទៅកាន់សិស្ស ហើយសុំលេខទូរស័ព្ទមាតា

បិតារបស់ពួកគេ។ ក្នុងការរៀបចំនេះមានការពិបាកបន្តិចដោយមាតាបិតាខ្លះនៅទីប្រជុំជនមិនមានពេលវេលាចូលរួមក្នុងការពិភាក្សាក្រុមនេះ ហេតុដូច្នេះយើងត្រូវជួប ឬទូរស័ព្ទទៅកាន់សិស្សដដែលម្តងទៀតដើម្បីសុំលេខទូរស័ព្ទសិស្សដទៃទៀត ដើម្បីទាក់ទងទៅកាន់មាតាបិតារបស់ពួកគេ។

យើងបានធ្វើការពិភាក្សាក្រុមបានសរុបទាំងអស់ចំនួន២១ក្រុម ក្នុងនោះមាន១២ក្រុមយើងបានធ្វើការថតសម្លេងដោយមានការអនុញ្ញាតពីអ្នកចូលរួម។ ក្នុងការពិភាក្សាក្រុមទាំងអស់មានអ្នកចូលរួមសរុបទាំងអស់១១៨នាក់ ដែលក្នុងនោះសិស្សរៀនគួមានចំនួន៣៨នាក់ សិស្សដែលមិនបានរៀនគួចំនួន៣១នាក់ គ្រូបង្រៀនគួចំនួន១៤នាក់ គ្រូមិនបានបង្រៀនគួចំនួន១២នាក់ មាតាបិតារបស់សិស្សដែលរៀនគួចំនួន៩នាក់ មាតាបិតារបស់សិស្សដែលមិនបានរៀនគួចំនួន១៤នាក់។ ការចូលរួមក្នុងក្រុមពិភាក្សាមានសិស្ស (ថ្នាក់ទី៦) ៥០នាក់ និងគ្រូ២០នាក់មកពីកម្រិតបឋមសិក្សាហើយសិស្ស(ថ្នាក់ទី៩) ១៩នាក់ និងគ្រូ៦នាក់ពីកម្រិតអនុវិទ្យាល័យ។ សម្រាប់មាតាបិតាយើងមិនមានការបែងចែកថាមកពីកម្រិតបឋមសិក្សា ឬអនុវិទ្យាល័យទេ ដោយសារពួកគាត់មានកូនរៀននៅកម្រិតផ្សេងគ្នា ហើយការផ្តល់ព័ត៌មានរបស់ពួកគាត់មិនសង្កត់ធ្ងន់តែលើកូនដែលរៀនថ្នាក់ទី៦ ឬទី៩ទេ។ (សូមមើលចំនួនក្រុម និងអ្នកចូលរួមក្នុងក្រុមពិភាក្សានីមួយៗនៅក្នុងតារាង២ និង៣)

**តារាង២៖ ចំនួនក្រុមនិងអ្នកចូលរួមក្នុងក្រុមពិភាក្សានៅជនបទ**

| | **គ្រូបង្រៀន** | | **សិស្ស** | | **មាតាបិតាសិស្ស** | |
|---|---|---|---|---|---|---|
| | បង្រៀនគួ (ក្រុមពិភាក្សា) | មិនបង្រៀនគួ (ក្រុមពិភាក្សា) | បង្រៀនគួ (ក្រុមពិភាក្សា) | មិនបង្រៀនគួ (ក្រុមពិភាក្សា) | បង្រៀនគួ (ក្រុមពិភាក្សា) | មិនបង្រៀនគួ (ក្រុមពិភាក្សា) |
| **បឋម.** | - | ៧(២) | ១៤(២) | ១២(២) | - | - |
| **អនុ.** | - | - | - | ៧(១) | - | - |
| **បឋម. និងអនុ.** | ៨(១) | - | ៧(១) | - | ៩(១) | ១៤(២) |
| **សរុប** | ៨(១) | ៧(២) | ២១(៣) | ១៩(៣) | ៩(១) | ១៤(២) |

**តារាង៣៖ ចំនួនក្រុមនិងអ្នកចូលរួមក្នុងក្រុមពិភាក្សានៅជនបទ**

| | **គ្រូបង្រៀន** | | **សិស្ស** | | **មាតាបិតាសិស្ស** | |
|---|---|---|---|---|---|---|
| | បង្រៀនគួ (ក្រុមពិភាក្សា) | មិនបង្រៀនគួ (ក្រុមពិភាក្សា) | បង្រៀនគួ (ក្រុមពិភាក្សា) | មិនបង្រៀនគួ (ក្រុមពិភាក្សា) | បង្រៀនគួ (ក្រុមពិភាក្សា) | មិនបង្រៀនគួ (ក្រុមពិភាក្សា) |
| **បឋម.** | ៣(១) | ៥(១) | ១២(២) | ១២(២) | - | - |
| **អនុ.** | ៣(១) | - | ៥(១) | - | - | - |
| **បឋម. និងអនុ.** | - | - | - | - | ៥(១) | - |
| **សរុប** | **៦(២)** | **៥(១)** | **១៧(៣)** | **១២(២)** | **៥(១)** | **-** |

## ៣. ការតាមដានពិន្ទុ និងវត្តមានរបស់សិស្ស

យើងធ្វើការជាមួយសាលារៀនទាំងប្រាំមួយដដែល ដើម្បីធ្វើការប្រៀបធៀបលទ្ធផលនៃការសិក្សារបស់សិស្សរៀនគួ និងមិនរៀនគួ។ យើងមានកិច្ចព្រមព្រៀងជាមួយមន្ទីរអប់រំយុវជន និងកីឡា និងជាមួយសាលានីមួយៗសម្រាប់ការធ្វើការសិក្សាស្រាវជ្រាវនេះ។ យើងមានការអនុញ្ញាតពីសាលានីមួយៗឲ្យថតចម្លងពិន្ទុ និងបញ្ជីវត្តមានប្រចាំខែសិស្សថ្នាក់ទី៦ និងថ្នាក់ទី៩។ ប៉ុន្តែសាលារៀនដែលនៅទីជនបទយើងមានការពិបាកក្នុងការប្រមូលទិន្នន័យដោយសារនៅទីនោះគ្មានហាងថតចម្លង។ដូច្នេះ យើងត្រូវសុំខ្ចីសៀវភៅស្រង់ពិន្ទុរបស់លោកគ្រូអ្នកគ្រូដើម្បីយកមកថតចម្លងនៅឯទីប្រជុំជនឬពេលខ្លះយើងប្រើម៉ាស៊ីនថតបញ្ជីពិន្ទុដែលធ្វើឲ្យមានការពិបាកមើល។

យើងបានរៀបចំជាបញ្ជីវត្តមាន ដើម្បីសុំឲ្យលោកគ្រូ/អ្នកគ្រូបង្រៀនគួដែលយើងធ្វើការជាមួយជួយស្រង់វត្តមានសិស្សរៀនគួ ដើម្បីឲ្យដឹងថានរណាតើនរណាខ្លះទៅរៀនគួ ហើយបានញឹកញាប់ប៉ុណ្ណាក្នុងគោលបំណងដើម្បីប្រៀបធៀបមើលលទ្ធផលនៃការសិក្សានៅក្នុងសាលារដ្ឋរបស់ពួកគេ ទៅនឹងសិស្សដែលមិនបានរៀនគួ។ ការប្រៀបធៀបនេះយើងគ្រាន់តែចង់បង្ហាញថាតើការយល់ឃើញថាសិស្សដែលបានទៅរៀនគួពិតជាទទួល

បានលទ្ធផលល្អជាងសិស្សដែលមិនបានទៅរៀនគួមែនឬអត់តែប៉ុណ្ណោះ។ តាមរយៈ ការប្រៀបធៀបនេះយើងមិនអាចសន្និដ្ឋានបានថាសិស្សដែលរៀនគួ និងមិនរៀនគួមួយណាមានចំណេះដឹងពិតប្រាកដខ្ពស់ជាងមួយណាទេដោយសារយើងប្រៀបធៀបមើលតែពិន្ទុប្រចាំខែមួយខែប៉ុណ្ណោះ ហើយការដាក់ប្រធានប្រលងនិងការដាក់ពិន្ទុប្រចាំខែមិនទាន់មានលក្ខណៈបទដ្ឋាន មានន័យថាប្រធានប្រលងដែលចេញពេលប្រលងប្រចាំខែក្នុងកម្រិតនីមួយៗមិនដូចគ្នាដូចជាប្រធានពេលប្រលងថ្នាក់ជាតិដែលចេញដោយក្រសួង ឬមន្ទីរនោះទេ។

យើងធ្វើការតាមដានវត្តមាន និងពិន្ទុប្រចាំខែមួយខែ ទៅលើសិស្សនៅបឋមសិក្សាចំនួន៤ថ្នាក់ មានសិស្សសរុបចំនួន១៦២នាក់ ដែលក្នុងនោះសិស្សទៅរៀនគួមានចំនួន៦៧នាក់ ស្មើនឹង៤១.៣៥% (សូមមើលតារាងទី ៤)។ យើងក៏បានធ្វើការតាមដានវត្តមាន និងពិន្ទុប្រចាំខែមួយខែទៅលើសិស្សអនុវិទ្យាល័យផងដែរ ដែលមានចំនួនសរុប២៨២នាក់ (សិស្សខ្លះអាចទៅរៀនគួច្រើនជាងមួយមុខវិជ្ជា) ដែលមានចំនួន៣ថ្នាក់នៅទីជនបទ និង៣ថ្នាក់ទៀតនៅទីប្រជុំជន ហើយក្នុងនោះមុខវិជ្ជាគណិតវិទ្យាមានសិស្សចំនួន៩៨នាក់ ស្មើនឹង៥៧.៣១% ទៅរៀនគួក្នុងចំណោមសិស្ស១៧១នាក់ មុខវិជ្ជាគីមីវិទ្យាមានសិស្សចំនួន៧៧នាក់ស្មើនឹង៣៧.០២% ទៅរៀនគួក្នុងចំណោមសិស្ស២០៨នាក់ មុខវិជ្ជាភាសាខ្មែរមានចំនួន១១១នាក់ស្មើនឹង៥៤.៦៨% ទៅរៀនគួក្នុងចំណោមសិស្ស២០៣នាក់ (សូមមើលតារាងទី ៥)។

**តារាង៤៖ ចំនួនសំណាកសិស្សដែលត្រូវបានតាមដានវត្តមាន និងពិន្ទុ នៅបឋមសិក្សា**

| | **គណិតវិទ្យា** | | |
|---|---|---|---|
| | ថ្នាក់រដ្ឋ | ថ្នាក់គួ | ភាគរយ |
| **ទីប្រជុំជន** | ៧១ | ៤៣ | ៦០.៥៣ |
| **ទីជនបទ** | ៩១ | ២៤ | ២៦.៣៧ |
| **សរុប** | **១៦២** | **៦៧** | **៤១.៣៥** |

| តារាង៥៖ ចំនួនសំណាកសិស្សដែលត្រូវបានតាមដានវត្តមាន និងពិន្ទុ នៅអនុវិទ្យាល័យ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | **គណិតវិទ្យា** | | | **គណិតវិទ្យា** | | | **គណិតវិទ្យា** | | |
| | ថ្នាក់រដ្ឋ | ថ្នាក់គួ | ភាគរយ | ថ្នាក់រដ្ឋ | ថ្នាក់គួ | ភាគរយ | ថ្នាក់រដ្ឋ | ថ្នាក់គួ | ភាគរយ |
| **ទីប្រជុំជន** | ៥៨ | ៣៥ | ៦០.៣៤ | ៩៥ | ៥៨ | ៦១.០៥ | ៩០ | ៤៧ | ៥២.២២ |
| **ទីជនបទ** | ១១៣ | ៦៣ | ៥៥.៧៥ | ១១៣ | ១៩ | ១៦.៨១ | ១១៣ | ៦៤ | ៥៦.៦៤ |
| **សរុប** | **១៧១** | **៩៨** | **៥៧.៣១** | **២០៨** | **៧៧** | **៣៧.០២** | **២០៣** | **១១១** | **៥៤.៦៨** |

ការស្រាវជ្រាវនេះ គ្រាន់តែពឹងផ្អែកលើទិន្នន័យ ដែលបានមកពី សាលាចំនួន ៦ ប៉ុណ្ណោះ។ ហេតុដូច្នេះហើយ យើងមិនអាចសន្និដ្ឋានបានថា សាលារៀនទាំងអស់នៅក្នុងប្រទេសកម្ពុជាមានលក្ខណៈដូចគ្នានឹងសាលារៀនដែលយើងបានចុះធ្វើការស្រាវជ្រាវបានទេ ដោយសារភាគសំណាកមានចំនួនតិចពេលគឺអនុវិទ្យាល័យមានចំនួនតែពីរ និងបឋមសិក្សាចំនួន៤ ហើយស្ថិតនៅក្នុងមួយស្រុកប៉ុណ្ណោះ។ការសង្កេតធ្វើបានតែចំនួន២៨ថ្នាក់ ហើយយើងធ្វើការតាមដានពិន្ទុបានតែមួយខែប៉ុណ្ណោះ។ ម៉្យាងទៀត ដោយសារមានពេលខ្លះ មានការពិបាកនៅក្នុងការជ្រើសរើសភាគសំណាក ទើបយើងបានសុំឲ្យ គ្រូបង្រៀន ឬនាយកសាលាជួយជ្រើសរើស។ ត្រង់ចំណុចនេះ គាត់អាចនឹងរើសភាគសំណាកដោយចេតនា ឬបង្គាប់អ្នកដែលគាត់រើសឲ្យនិយាយអ្វីដែលគាត់ចង់ឲ្យនិយាយ។ហេតុដូចនេះព័ត៌មានខ្លះ ដែលទទួលបានអាចមិនពិត។ ទោះ បីមានបញ្ហាយ៉ាងនេះក៏ដោយ ក៏ទិន្នន័យដែលយើងប្រើនេះ នៅតែអាចទុកចិត្តបាន ដោយសារយើងបានប្រើប្រាស់វិធីសាស្ត្រផ្សេងៗ ដើម្បីប្រមូលទិន្នន័យមកផ្ទៀងផ្ទាត់គ្នា។

## របកគំហើញ

### ភាពខុសគ្នារវាងពិន្ទុរបស់សិស្សរៀនគួ និងមិនរៀនគួ

នៅក្នុងការតាមដានពិន្ទុរបស់សិស្សដែលទៅរៀនគួ និងមិនទៅរៀនគួគ្រាន់តែបង្ហាញនូវភាពខុសគ្នារវាងពិន្ទុរបស់ពួកគេប៉ុណ្ណោះហើយដោយផ្អែកលើភាពខុសគ្នានេះតែមួយមុខ យើងមិនអាចសន្និដ្ឋានបានថាសិស្សណា ចេះជាងសិស្សណាទេ។ ការតាមដានពិន្ទុ របស់សិស្សលើសិស្សថ្នាក់ទី៩ ចំនួន ២៨២នាក់និងសិស្សថ្នាក់ទី៦ ចំនួន១៦២នាក់ បានបង្ហាញថា សិស្សដែលបានទៅរៀនគួ មានពិន្ទុច្រើនជាងសិស្សដែលមិនទៅរៀនគួ យ៉ាងហោចណាស់ មួយពិន្ទុ ។ នៅក្នុងទិន្នន័យដែលបង្ហាញនេះ សិស្សរៀនគួ ជាសិស្សដែលបានចូលរួមក្នុងថ្នាក់គួ យ៉ាងហោចណាស់ម្តងក្នុងអំឡុងខ នៅក្នុងការតាមដានពិន្ទុរបស់សិស្សដែលទៅរៀនគួ និងមិនទៅរៀនគួគ្រាន់តែបង្ហាញនូវភាពខុសគ្នារវាងពិន្ទុរបស់ពួកគេប៉ុណ្ណោះ ហើយដោយផ្អែកលើភាពខុសគ្នានេះតែមួយមុខ យើងមិនអាចសន្និដ្ឋានបានថាសិស្សណាចេះជាងសិស្សណាទេ។ ការតាមដានពិន្ទុរបស់សិស្សលើសិស្សថ្នាក់ទី៩ ចំនួន២៨២នាក់ និងសិស្សថ្នាក់ទី៦ ចំនួន១៦២នាក់បានបង្ហាញថា សិស្សដែលបានទៅរៀនគួ មានពិន្ទុច្រើនជាងសិស្សដែលមិនទៅរៀនគួ យ៉ាងហោចណាស់ មួយ ពិន្ទុ ។ នៅក្នុងទិន្នន័យដែលបង្ហាញនេះ សិស្សរៀនគួ ជាសិស្សដែលបានចូលរួមក្នុងថ្នាក់គួ យ៉ាងហោចណាស់ម្តង ក្នុងអំឡុងខែដែលធ្វើការតាមដាន។ រីឯសិស្សអត់រៀនគួ ជាសិស្សដែលមិនបានចូលរួមក្នុងថ្នាក់គួណាមួយទាល់តែសោះ។

**ក្រាហ្វ១៖**




នៅថ្នាក់ទី ៩ នៃសាលាជនបទដែលយើងតាមដាន សិស្សរៀនគួបានពិន្ទុច្រើនជាងសិស្សដែលមិនបានរៀនគួសម្រាប់មុខវិជ្ជាគណិតវិទ្យា និងភាសាខ្មែរ (ក្រាហ្វ ១)។ ប៉ុន្តែសម្រាប់ មុខវិជ្ជាគីមីវិទ្យា វាមានភាពផ្ទុយទៅវិញ ដោយសិស្សដែលមិនបាន


Vowels
a e i o u

រៀនគួ ទទួលបានពិន្ទុច្រើនជាងសិស្សដែលរៀនគួ។ ចំពោះរឿងនេះ យើងអាចពន្យល់បានពីរយ៉ាង។ ទី១ គឺសិស្សដែលរៀនគួគីមីវិទ្យាទាំងអស់ ជាសិស្សដែលឧបត្ថម្ភដោយអង្គការក្រៅរដ្ឋាភិបាលមួយ។ ប្រសិនបើគ្មានការឧបត្ថម្ភថវិកាពីអង្គការទេ ទំនងជាគ្មានសិស្សណាម្នាក់ទៅរៀនមុខវិជ្ជានេះដែរ ព្រោះយើងអាចសន្និដ្ឋានថា វាមានភាពងាយស្រួលសម្រាប់សិស្សទាំងអស់ ក្នុងការទទួលបាននូវពិន្ទុខ្ពស់ ចំពោះមុខវិជ្ជានេះ តាមរយៈការសង្កត់មើលពិន្ទុរបស់សិស្សទាំងអស់។ យើងសង្កេតឃើញថា ពិន្ទុមុខវិជ្ជានេះរបស់សិស្សរៀនគួ និងមិនរៀនគួស្ថិតក្នុងចំណាត់ថ្នាក់ល្អទាំងអស់គ្នា ដែលនេះធ្វើឲ្យមិនសូវមានតម្រូវការសម្រាប់ការរៀនគួ។ ភាពងាយស្រួលក្នុងការទទួលបានពិន្ទុល្អ សម្រាប់មុខវិជ្ជានេះ យើងមិនអាចសន្និដ្ឋានថាមកពីមូលហេតុណាមួយឲ្យប្រាកដនោះទេ ព្រោះថាគ្រូជាអ្នករៀបចំ និងឲ្យពិន្ទុការប្រលងប្រចាំខែដោយខ្លួនឯង ហើយម្យ៉ាងទៀត យើងទទួលបានតែពិន្ទុប្រលងប៉ុណ្ណោះ មិនបានទទួលវិញ្ញាសាប្រលងទេ។ ហេតុដូចច្នេះ យើងមិនអាចវាយតម្លៃកម្រិតរបស់វិញ្ញាសា ឬភាពសុក្រិតនៃការឲ្យពិន្ទុបានទេ។

នៅថ្នាក់ទី៩ នៃសាលាដែលនៅក្នុងក្រុង យើងក៏បានរកឃើញនូវភាពខុសគ្នានៃពិន្ទុរបស់សិស្សរៀនគួ និងសិស្សដែលមិនបានរៀនគួ ហើយភាពខុសគ្នានេះក៏មានលក្ខណៈខ្លាំងគួរឲ្យកត់សម្គាល់ផងដែរ (ក្រាហ្វ ២)។ មុខវិជ្ជាដែលខុសគ្នាខ្លាំងបំផុតនោះគឺគណិតវិទ្យា និងភាសាខ្មែរ។ សិស្សដែលរៀនគួមុខវិជ្ជាទាំងពីរនេះ ទទួលបានពិន្ទុជាមធ្យមច្រើនជាងសិស្សដែលមិនបានទៅរៀនគួពីរដង។មុខវិជ្ជាគណិតវិទ្យា និងមុខវិជ្ជាភាសាខ្មែរមានឥទ្ធិពលលើលទ្ធផលនៃការសិក្សាទាំងមូលរបស់សិស្ស ខ្លាំងជាងមុខវិជ្ជាដទៃទៀត ដោយសារមុខវិជ្ជាទាំងពីរនេះ មានពិន្ទុអតិបរមាច្រើនជាងពិន្ទុមុខវិជ្ជាដទៃទៀតពីរដងពោលគឺគណិតវិទ្យា និងភាសាខ្មែរមានពិន្ទុ ១០០ រីឯមុខវិជ្ជាដទៃទៀត រួមទាំងគីមីវិទ្យាផងដែរមានពិន្ទុ ៥០ ហើយពិន្ទុនេះ ក៏ធ្វើឲ្យមានតម្រូវការនៃការរៀនគួខ្លាំងផងដែរ។ បើយើងប្រៀបធៀបទិន្នន័យទាំងពីរនេះ យើងសង្កេតឃើញថាមានភាពខុសគ្នាខ្លាំងផងដែររវាងជនបទ និងទីប្រជុំជន។

## ក្រាហ្វ ២៖

## ពិន្ទុប្រចាំខែជាមធ្យមរបស់សិស្សអនុវិទ្យាល័យនៅទីប្រជុំជន




*ចំណាំ: នៅក្នុងការគណនានេះ សិស្សរៀនគួជាសិស្សដែលចូលរួមក្នុងថ្នាក់រៀនគួយ៉ាងហោចណាស់ម្តង ក្នុងខែដែលយើងតាមដាន។

## កម្មវិធីសិក្សា

ទិន្នន័យនៅក្នុងតារាងខាងក្រោមបានមកពីការង្កេតថ្នាក់រៀន ហើយបង្ហាញថា សកម្មភាព នៃដំណើរការរៀននិងបង្រៀនទាំងនៅក្នុងថ្នាក់រដ្ឋ និងថ្នាក់គួមានភាពស្រដៀងគ្នា (ភាគរយ)។ ទិន្នន័យនេះ រួមផ្សំជាមួយនឹងទិន្នន័យពីការពិភាក្សាក្រុមអាចធ្វើឲ្យយើងសន្និដ្ឋានបានថា ការរៀនគួ ត្រង់ចំណុចជាច្រើន គឺជាការបន្ត (វិធីសាស្រ្តបង្រៀន និងកម្មវិធីសិក្សា) ពីថ្នាក់រដ្ឋ (សូមមើលតារាង ៦)។ ជាឧទាហរណ៍ ភាគរយនៃការដាក់កិច្ចការឲ្យសិស្សធ្វើនៅផ្ទះ របស់គ្រូបង្រៀនមានលក្ខណៈប្រហាក់ប្រហែលគ្នា (៥៣% ចំនួនថ្នាក់រៀនគួដែលបានសង្កេត និង ៦៥% នៅក្នុងថ្នាក់រដ្ឋ) ក៏ដូចជាការឲ្យឧទាហរណ៍ទៅសិស្សទាំងអស់ ក៏មានលក្ខណៈដូចគ្នាដែរ (៧៨% ទាំងនៅថ្នាក់គួ និងនៅថ្នាក់រដ្ឋ)។ ស្រដៀងគ្នាដែរ សិស្សមានការចូលរួមសកម្មភាពដូចគ្នាទាំងនៅក្នុងថ្នាក់រៀនគួ និងថ្នាក់រដ្ឋដូចជាការឆ្លើយសំណួរពហុជ្រើសរើស (១៥ ភាគរយ) និងសិស្សឆ្លើយព្រមគ្នា (៧១% នៅថ្នាក់រដ្ឋ និង៦៥% នៅថ្នាក់គួ)។



| **តារាង៦៖ ភាពស្រដៀងគ្នានៅក្នុងថ្នាក់រដ្ឋ និងថ្នាក់រៀនគូ** | | |
|---|---|---|
| **គរុកោសល្យគ្រូបង្រៀន** | **ថ្នាក់រដ្ឋ N=១៤**<br><br>**ភាគរយថ្នាក់ដែលបានសង្កេត(ចំនួនថ្នាក់ដែលបានសង្កេត)** | **ថ្នាក់គូ N=១៤**<br><br>**ភាគរយថ្នាក់ដែលបានសង្កេត(ចំនួនថ្នាក់ដែលបានសង្កេត)** |
| សិស្សពូកែធ្វើការជាមួយសិស្សខ្សោយ | ២៨.៦(៤) | ១៤.៣(២) |
| សិស្សពូកែជួយបង្រៀនសិស្សក្នុងថ្នាក់ | ៧១.៤(១០) | ៥០(៧) |
| ហៅសិស្សខ្សោយឲ្យឆ្លើយសំណួរ | ៥០(៧) | ៤២.៩(៦) |
| សិស្សឆ្លើយសំណួរពហុជ្រើសរើស | ១៤.៣(២) | ១៤.៣(២) |
| សិស្សធ្វើការនៅក្ដារខៀន | ១០០(១៤) | ៧១.៤(១០) |
| ដាក់កិច្ចការឲ្យធ្វើនៅផ្ទះ | ៦៤.៣(៩) | ៤២.៩(៦) |
| គ្រូបង្រៀនចំណុចថ្មី | ៧៨.៦(១១) | ៣៥.៧(៥) |
| គ្រូណែនាំសិស្សឲ្យធ្វើសកម្មភាព | ១០០(១៤) | ៨៥.៧(១២) |
| សិស្សឆ្លើយព្រមគ្នា | ៧១.៤(១០) | ៦៤.៣(៩) |
| គ្រូឲ្យឧទាហរណ៍ទៅសិស្សទាំងអស់ | ៧៨.៦(១១) | ៧៨.៦(១១) |

ទិន្នន័យដែលបានមកពីការធ្វើការពិភាក្សាក្រុមបានបង្ហាញថាពេលវេលាសម្រាប់ការបង្រៀន និងរៀននៅសាលារដ្ឋនាពេលបច្ចុប្បន្ននេះ ជាទូទៅមិនអាចអនុញ្ញាតឲ្យគ្រូបង្រៀនបញ្ចប់កម្មវិធីសិក្សាតាមការកំណត់របស់ក្រសួងបានទេ ហើយសិស្សភាគច្រើនក៏មិនអាចទទួលចំណេះដឹងបានគ្រប់គ្រាន់ដោយគ្រាន់តែទៅសិក្សានៅក្នុងថ្នាក់រៀនរដ្ឋ

ដែរ។ ការបង្រៀនត្រូវបានផ្តោតសំខាន់ទៅលើការបញ្ចប់កម្មវិធីសិក្សា ជាជាងគុណភាពនៃការអប់រំដែលសិស្សត្រូវទទួល។ គ្រូបង្រៀនមួយចំនួនត្រូវពន្លឿនការបង្រៀនដើម្បីបញ្ចប់កម្មវិធីសិក្សារបស់ក្រសួងឲ្យបានទាន់ពេលវេលា ដោយធ្វើការសង្ខេប ឬកាត់បន្ថយផ្នែកខ្លះនៃមេរៀនរបស់គាត់។ គ្រូបង្រៀនម្នាក់ក្នុងចំណោម គ្រូបង្រៀនដែលចូលរួមក្នុងការពិភាក្សាក្រុមបានមានប្រសាសន៍ថា៖ "យើងអាចសង្ខេបយកចំណុចណាដែលសំខាន់ៗ ដូចជាមួយមេរៀនមានមួយទំព័រ យើងអាចសង្ខេបត្រឹមបួនប្រាំបន្ទាត់មក ដើម្បីបង្រៀន។" ការបង្រៀនស្រួតបែបនេះ មិនមែនមានន័យថាសិស្សទាំងអស់សុទ្ធតែមិនទទួលបាននូវអ្វីដែលគ្រូបានបង្រៀននោះទេ។ សម្រាប់សិស្សដែលត្រូវបានចាត់ទុកថាជាសិស្សឆ្លាត ឬពូកែអាចតាមទាន់នូវអ្វីដែលគ្រូបានបង្រៀន ប៉ុន្តែសម្រាប់សិស្សខ្សោយវិញប្រាកដជាមានការលំបាកក្នុងតាមឲ្យទាន់ ចំពោះការបង្រៀនបែបនេះណាស់។ គ្រូបង្រៀនដដែលនោះ បានបន្ថែមថា៖ "ប្រសិនបើយើងបង្រៀនយកលឿនតាមកម្មវិធីគេ សិស្សអាច ចំណេះដឹងនោះ អាចវា... គុណភាពវាខ្សោយ ហើយអ្នកពូកែចេះតែទៅមុខ។"

នៅពេលដំណាលគ្នានេះដែរ គ្រូបង្រៀនមួយចំនួនទៀតមិនបានយកចិត្តទុកដាក់ខ្លាំងទៅលើការបញ្ចប់កម្មវិធីសិក្សា តាមការកំណត់របស់ក្រសួងនោះទេ ដោយគាត់យល់ថា ពេលវេលាដែលក្រសួងផ្តល់ឲ្យមានចំនួនតិចតួចពេក ដែលនឹងអាចឲ្យគាត់សម្រេចការងារនេះបាន។ ជាក់ស្តែងមានគ្រូបង្រៀនម្នាក់បានលើកឡើងថា៖ "ឲ្យតិចអញ្ចឹង ខ្ញុំបង្រៀនតាមដំណើរ អត់ចប់កម្មវិធីអត់ទៅ ព្រោះអីម៉ោងវាតិច ខំយ៉ាងម៉េចក៏ទៅអត់រួច។"

ក្នុងការពិភាក្សាក្រុម ទាំងគ្រូបង្រៀន និងសិស្សបានអះអាងថា ទ្រឹស្តីត្រូវបានលើកយកមកបង្រៀនច្រើនជាងការអនុវត្ត។គ្រូបង្រៀនបានកាត់បន្ថយការអនុវត្តលើលំហាត់ដែលមាននៅក្នុងសៀវភៅពុម្ពរបស់ក្រសួង ដោយផ្តោតភាគច្រើនទៅលើទ្រឹស្តីដើម្បីបញ្ចប់កម្មវិធីសិក្សា ដោយគាត់យល់ថាកម្មវិធីសិក្សាមានលក្ខណៈវែងពេកសម្រាប់រយៈពេលក្នុងម៉ោងរដ្ឋ ដែលក្រសួងបានកំណត់ឲ្យ។ ពួកគាត់ពុំអាចលើកយកលំហាត់ដែលមាននៅក្នុងសៀវភៅពុម្ពមកអនុវត្តឲ្យបានទាំងអស់នោះទេ ដោយលំហាត់ដែលនៅសល់ខ្លះត្រូវបានដាក់

ឲ្យសិស្សធ្វើនៅផ្ទះ ខ្លះទៀតកាត់ចោល ឬយកទៅបង្រៀននៅថ្នាក់គួ ។ គ្រូបង្រៀនម្នាក់បានលើកឡើងថា មានលំហាត់ចំនួនប្រាំពីរដែលមាននៅក្នុងសៀវភៅពុម្ព ប៉ុន្តែដោយសារពេលវេលាមិនគ្រប់គ្រាន់ ទើបគាត់បង្រៀនបានតែពីរប៉ុណ្ណោះ។ គាត់បានបន្ថែមទៀតថាលំហាត់ទាំងប្រាំពីរមានកម្រិតពីស្រួលទៅលំបាក ហើយលំហាត់ចុងក្រោយសម្រាប់ផ្សារភ្ជាប់ទៅមេរៀនបន្ទាប់ ដែលមានន័យថាគាត់គួតែបង្រៀនលំហាត់ទាំងប្រាំពីរ។

នេះជាបញ្ហាមួយ ដែលជំរុញឲ្យសិស្សទៅរៀនគួ ដើម្បីបង្គ្រប់ចំណេះដឹងរបស់ពួកគេ។ នៅក្នុងថ្នាក់រៀនគួ គ្រូបង្រៀនបានផ្តោតទៅលើការអនុវត្តច្រើន និងលើទ្រឹស្តីតែបន្តិចបន្តួចប៉ុណ្ណោះ។ ក្នុងការបង្រៀនគួ គ្រូបង្រៀនបានបន្តការអនុវត្តទ្រឹស្តីដែលបានរៀននៅសាលារដ្ឋ ដោយលើកយកលំហាត់នៅក្នុងសៀវភៅពុម្ពរបស់ក្រសួងដែលមិនទាន់បានបង្រៀនមកអនុវត្ត និងមានបន្ថែមលំហាត់ផ្សេងទៀត ដែលគាត់បានធ្វើការស្រាវជ្រាវពីប្រភពផ្សេងៗ។ គ្រូបង្រៀនម្នាក់បានលើកឡើងថា៖ "គេ [គ្រូដែលបង្រៀនគួ] យកមេរៀនដែលគេបានរៀនពីក្នុងថ្នាក់រួចហើយ ទៅអនុវត្តនៅពេលបង្រៀនគួច្រើនជាង គេអនុវត្តហើយ គេពង្រីកបន្ថែមទៀត។"

ទោះបីជាមានការអះអាងថា មានការអនុវត្តនៅក្នុងថ្នាក់រៀនគួ ច្រើនជាងនៅក្នុងថ្នាក់រដ្ឋក៏ដោយ តាមរយៈការសង្កេតលើសកម្មភាពនីមួយៗ នៅពេលដំណើរការបង្រៀន និងរៀនដែលមានបែងចែកជាសកម្មភាពអនុវត្តន៍ និងមិនអនុវត្តន៍ (សូមមើលតារាង ៧) យើងឃើញថាសកម្មភាពដែលអនុវត្ត នៅក្នុងការថ្នាក់រៀនគួមានរយៈពេលប្រហាក់ប្រហែលគ្នានឹងរយៈពេលនៃការអនុវត្តនៅក្នុងថ្នាក់រដ្ឋដែរ។ ប៉ុន្តែអ្វីដែលយើងអាចដឹងតាមរយៈការសង្កេតនេះ គឺនៅក្នុងថ្នាក់គួ គ្រូបង្រៀនប្រើវិធីសាស្រ្តនៃការអនុវត្តជាលក្ខណៈបុគ្គលជាជាងការប្រើការអនុវត្តជាក្រុម។ នៅក្នុងការអនុវត្តជាលក្ខណៈបុគ្គលនៅក្នុងថ្នាក់រៀនគួ គ្រូអាចជួយពន្យល់ជាលក្ខណៈបុគ្គលទៅកាន់សិស្សម្នាក់ៗ បានប្រសើរជាងនៅក្នុងថ្នាក់រដ្ឋ ដោយសារក្នុងថ្នាក់រៀនគួមានចំនួនសិស្សតិច។ ជាទូទៅការអនុវត្តបែបនេះ សិស្សគិតថាអាចទទួលបានគុណភាពល្អជាងនៅក្នុងថ្នាក់រៀនរដ្ឋ ដែលមានការលំបាកក្នុងការធ្វើបែបនេះ ដោយចំនួនសិស្សច្រើន។

**តារាង៧៖សកម្មភាពអនុវត្តន៍ និងមិនអនុវត្តន៍នៅក្នុងថ្នាក់រៀនគិតជាភាគរយ (នាទី) នៃចំនួនម៉ោងសិក្សាសរុបរបស់ថ្នាក់គូ ធៀបនឹង ថ្នាក់រៀនវេ្ង**

| សកម្មភាពដែលបានសង្កេត | | ថ្នាក់គូ N=៧ | ថ្នាក់វេ្ង N=៦ |
|---|---|---|---|
| **សកម្មភាពក្នុងថ្នាក់រៀនដែលមិនមែនជាការអនុវត្ត** | គ្រូបង្រៀនមេរៀន | ២៩.០៩ (១៦) | ២៩.៣១(១៧) |
| | សិស្សនិយាយលក្ខណៈបុគ្គល ឬទាំងអស់គ្នា | ៧.២៧ (៤) | ១០.៣៥(៦) |
| | ការគ្រប់គ្រងថ្នាក់រៀន (វត្តមាន គ្រូដាក់លំហាត់នៅផ្ទះ ការណែនាំទូទៅ និង/ឬប្រមូលប្រាក់ | ១៤.៥៥(៨) | ៨.៦២(៥) |
| | **សរុបរង** | **៥០.៩១(១៩៧)** | **៤៨.២៨(២៨)** |
| **សកម្មភាពក្នុងថ្នាក់រៀនដែលជាការអនុវត្ត** | សិស្ស/គ្រូដោះស្រាយលំហាត់ឧទាហរណ៍នៅក្តារខៀន | ២៩.០៩(១៦) | ២៧.៥៩(១៦) |
| | សិស្សដោះស្រាយលំហាត់ឧទាហរណ៍នៅកន្លែងអង្គុយ | ១៨.១៨(៦៧) | ៦.៨៩(៤) |
| | សិស្សដោះស្រាយលំហាត់ឧទាហរណ៍ជាក្រុម (ចាប់ពីបីនាក់) | ០.០០(០) | ១៧.២៤(១០) |
| | សិស្សធ្វើការជាគូ | ១.៨២(១) | ០.០០(០) |
| | **សរុបរង** | **៤០.០៩(២៧)** | **៥១.៧២(៣០)** |
| | **សរុប** | **១០០(៥៥)** | **១០០(៥៨)** |

## បរិមាណសិស្សនៅក្នុងថ្នាក់រៀន

កត្តាមួយទៀតដែលជំរុញឲ្យសិស្សទៅរៀនគួគឺចំនួនសិស្សច្រើនពេកនៅក្នុងថ្នាក់រៀនរដ្ឋនីមួយៗ។ សិស្សទាំងអស់នៅក្នុងថ្នាក់រៀនពុំមានឱកាសគ្រប់គ្នាដើម្បីអនុវត្តទ្រឹស្តីដែលបានរៀនទេ ដោយសារចំនួនសិស្សនៅក្នុងថ្នាក់នីមួយៗ មានចំនួនច្រើនពេក។ នេះជាចំណុចមួយដែលបង្កការលំបាកដល់ដំណើរការនៃបង្រៀន និងរៀន ដែលធ្វើឲ្យសិស្សមិនអាចយល់មេរៀនបានល្អដោយសារភាពឡូឡាដែលងាយនឹងអាចកើតឡើង ហើយគ្រូបង្រៀនក៏ពុំអាចពន្យល់បានគ្រប់ជ្រុងជ្រោយទៅកាន់សិស្សទាំងអស់នោះដែរ។ សិស្សម្នាក់បានរអ៊ូថា៖ "ខ្ញុំរៀនក្នុងថ្នាក់មិនសូវចូល ហើយណាមួយសិស្សក្នុងថ្នាក់មានច្រើនពេក។" ចំណុចនេះឪពុកម្តាយរបស់សិស្សក៏បានលើកឡើងផងដែរថាចំនួនសិស្សច្រើននៅក្នុងថ្នាក់ធ្វើឲ្យការពន្យល់របស់គ្រូកាន់សិស្សពុំមានលក្ខណៈគ្រប់គ្រាន់។ ម៉្យាងទៀត គ្រូបង្រៀនក៏បានបញ្ជាក់ផងដែរថា បើចង់ឲ្យគុណភាពអប់រំកាន់តែប្រសើរ ទាល់តែកាត់បន្ថយចំនួនសិស្សនៅក្នុងថ្នាក់ឲ្យមកនៅត្រឹម ២៥នាក់ ឬតិចជាងនេះ៖ "... សិស្សច្រើន បើចង់ឲ្យមានស្តង់ដា ទាល់តែ ២៥នាក់បានមានស្តង់ដា [មាន]គុណភាពខ្លះ"។ ចំណុចនេះដែលធ្វើឲ្យសិស្សបែរទៅការរៀនគួ ដែលគេមើលឃើញថាមានគ្នាតិចជាងនៅក្នុងថ្នាក់រដ្ឋ ហើយមានឱកាសបានអនុវត្តលំហាត់ច្រើន និងគ្រប់ៗគ្នា។

នៅក្នុងការស្រាវជ្រាវនេះ ភាពខុសគ្នារវាងចំនួនសិស្សក្នុងថ្នាក់រដ្ឋ និងថ្នាក់រៀនគួត្រូវបានរកឃើញផងដែរ។ ដោយផ្អែកលើការសង្កេត និងការតាមដានពិន្ទុ ចំនួនសិស្សជាមធ្យមក្នុងមួយថ្នាក់នៅថ្នាក់ទី៩ នៅសាលារដ្ឋមានចំនួន ៤២នាក់ ( ទាំងនៅជនបទ និងទីក្រុង ) ហើយនៅក្នុងថ្នាក់រៀនគួជាមធ្យមមានចំនួន ២១នាក់។ បើយើងបង្ហាញទិន្នន័យទៅតាមទីកន្លែង ចំនួនសិស្សជាមធ្យមក្នុងមួយថ្នាក់នៅអនុវិទ្យាល័យ ( ថ្នាក់ទី៩ ) ក្នុងក្រុងមានចំនួន ៥៦នាក់ និងនៅជនបទមានចំនួន ៣៥នាក់ ហើយសិស្សអនុវិទ្យាល័យដែលរៀនគួក្នុងមួយថ្នាក់នៅក្នុងក្រុងមានចំនួន ៣៧នាក់ និង ១៧នាក់ នៅជនបទ។ ម៉្យាងទៀតតួលេខសិស្សជាមធ្យមរបស់សិស្សថ្នាក់ទី ៦ ក្នុងមួយថ្នាក់ នៃសាលារដ្ឋនៅក្នុងក្រុង គឺ ៣១នាក់ ចំណែកឯនៅថ្នាក់រៀនគួវិញគឺ ១៧នាក់។ តួលេខទាំងនេះបង្ហាញថាចំនួនសិស្សនៅក្នុងថ្នាក់រៀនគួ តិចជាងចំនួនសិស្សនៅក្នុងថ្នាក់រៀនរដ្ឋ មិនថានៅជនបទ ឬនៅទីក្រុងទេ។

# ការចូលរួមចំណែកពីគ្រួសារ ក្នុងការសិក្សារបស់សិស្ស

ការចូលរួមចំណែករបស់ក្រុមគ្រួសារទៅលើការសិក្សារបស់កូន ជាផ្នែកមួយដែលត្រូវបានចាត់ទុកថាមានសារៈសំខាន់ដែរសម្រាប់ការអប់រំរបស់សិស្ស។ "ការចូលរួមចំណែក" របស់ក្រុមគ្រួសារ ក្នុងការសិក្សារបស់សិស្សត្រង់ចំណុចនេះមានន័យថា គ្រួសារយល់ព្រមបញ្ជូន ឬអនុញ្ញាតឲ្យកូនរបស់គាត់ទៅរៀនគួ ឬអញ្ជើញគ្រូឲ្យមកបង្រៀនគួកូនរបស់គាត់ដល់ផ្ទះ និងមានការតាមដានការសិក្សារបស់កូនគាត់។ ចំណែកឯពាក្យ "គ្រួសារ" គឺសំដៅទៅឪពុក និង/ឬម្ដាយ ព្រោះមិនប្រាកដថាទាំងឪពុក និងទាំងម្ដាយទេ ដែលបានដឹងអំពីការសិក្សារបស់កូនគាត់ ដូចជាមានឪពុកខ្លះបានដឹងកូនរបស់គាត់រៀនគួមុខវិជ្ជាអ្វីខ្លះ តែគាត់ពុំបានដឹងអំពីការចំណាយទៅលើការរៀនគួទាំងនេះទេ ដោយសារការចំណាយនេះគឺភរិយារបស់គាត់ជាអ្នកចាត់ចែង។ នេះអាចមកពីទម្លាប់របស់ក្រុមគ្រួសារនៅប្រទេសកម្ពុជា ដែលស្ត្រីជាអ្នកថែរក្សាលុយកាក់ និងទ្រព្យសម្បត្តិផ្សេងៗនៅក្នុងផ្ទះ និងទទួលខុសត្រូវលើការចំណាយនៅក្នុងក្រុមគ្រួសារ។

មានគ្រួសារមួយចំនួនបានចូលរួមចំណែកយ៉ាងសកម្មក្នុងការសិក្សារបស់កូនពួកគាត់ ប៉ុន្តែក្រុមគ្រួសារខ្លះត្រូវបានយល់ឃើញមិនបានចូលរួមចំណែកទេ ឬចូលរួមចំណែកតិចតួចប៉ុណ្ណោះ។ នៅក្នុងការពិភាក្សាក្រុមជាមួយអាណាព្យាបាលសិស្ស ឪពុកម្ដាយខ្លះបានដឹងអំពីការសិក្សាដូចជាកូនរបស់គាត់បានរៀនអ្វីខ្លះ រៀនពូកែ ឬខ្សោយ (បានចំណាត់ថ្នាក់លេខប៉ុន្មាន) ការចំណាយប្រចាំខែលើការសិក្សាកូនរបស់គាត់ម្នាក់ៗអស់ប៉ុន្មានជាដើម។ រីឯឪពុកម្ដាយខ្លះទៀតពុំបានដឹង ឬដឹងតិចតួចប៉ុណ្ណោះអំពីការសិក្សារបស់កូនគាត់ ដូចជាគាត់គ្រាន់តែដឹងថាកូនរបស់គាត់ទៅរៀនតែមិនបានដឹងថារៀនអ្វីខ្លះនោះទេ។

គ្រូបង្រៀនបានយល់ឃើញថាសិស្សដែលបានទៅរៀនគួ និងសិស្សដែលរៀនពូកែភាគច្រើនមានការរួមចំណែកពីក្រុមគ្រួសារ ដោយពួកគាត់ (គ្រូបង្រៀន)បានលើកឡើងអំពីការអនុញ្ញាតឲ្យកូនមករៀនគួ ជួយជំរុញកូនឲ្យមកសាលាឲ្យបានទៀងទាត់ ជួយជំរុញកូនឲ្យសិក្សាបន្ថែមនៅផ្ទះ  ផ្ដល់ពេលវេលាគ្រប់គ្រាន់សម្រាប់ការសិក្សារបស់កូនគាត់ជាដើម។ ជាក់ស្ដែងនៅក្នុងការពិភាក្សាក្រុមគ្រូបង្រៀនម្នាក់គាត់ដកស្រង់ពាក្យសម្ដីរបស់អាណាព្យាបាលសិស្សម្នាក់ដែលចង់ឲ្យកូនគាត់ទៅរៀនគួថា៖ "អ្នកគ្រូ មិនបានបង្រៀនគួទេអ្ហេ?" ។ នេះបង្ហាញឲ្យឃើញពី



តម្រូវការនៃការរៀនគួពីគ្រួសារសិស្ស។ មានពេលខ្លះឪពុកម្ដាយមិនបានបង្ហាញពីការចូលរួមចំណែកដោយផ្ទាល់ដូច្នេះទេ តែគាត់បង្ហាញតាមរយៈការអនុញ្ញាតឲ្យកូនរបស់គាត់ទៅរៀនគួ ដោយបានផ្ដល់ជាថវិកា និងពេលវេលាសម្រាប់ការរៀនគួនេះជាដើម។ គ្រូបង្រៀនម្នាក់បានលើកឡើងថា ប្រសិនបើឪពុកម្ដាយឆ្លើយតបទៅកាន់សិស្សថា៖ "ទេ! គ្មានលុយទេ!" នោះការបង្រៀនគួក៏មិនអាចកើតមានឡើងដែរ។

បញ្ហាថវិកានេះជាមូលហេតុមួយ ក្នុងចំណោមមូលហេតុទាំងឡាយដែល ធ្វើឲ្យគ្រួសាររបស់សិស្សដែលមិនបានរៀនគួ ឬទៅរៀននៅសាលារដ្ឋមិនជាប់លាប់ត្រូវបានយល់ឃើញថា មិនសូវបានចូលរួមចំណែកក្នុងការសិក្សារបស់កូនគាត់។ នៅក្នុងការពិភាក្សាក្រុម មានការលើកឡើងថា សិស្សដែលទៅរៀនមិនបានជាប់លាប់ បណ្ដាលមកពីបញ្ហាជីវភាព និងការមិនយកចិត្តទុកដាក់ពីក្រុមគ្រួសារ។ គ្រូបង្រៀនម្នាក់បានមានប្រសាសន៍ថា៖ "ម៉ោងរដ្ឋយើងធម្មតា មិនមែនរៀនគួ តែសិស្សនោះភាគច្រើន ឧស្សាហ៍ឈប់ផង... មកពីបញ្ហាជីវភាពគ្រួសារនោះឯង... ម៉ែឪមិនសូវយកចិត្តទុកដាក់ផង មកពីបញ្ហាជីវភាពផង បើថាកូនមិនមករៀន គឺអត់បង្ខំឲ្យកូនមកតែម្ដង"។ "ជីវភាព" សំដៅលើតម្រូវការចាំបាច់សម្រាប់ការរស់នៅប្រចាំថ្ងៃ ដូចជាការហូបចុក និងការស្លៀកពាក់ជាដើម។ ជីវភាព ត្រូវបានយល់ឃើញថាជាអាទិភាពសំខាន់ជាងការសិក្សារបស់កូនៗគាត់ ដូចដែលសិស្សម្នាក់បានអះអាងថា ម្ដាយរបស់នាងមិនមែនមិនអនុញ្ញាតឲ្យនាងទៅរៀនគួទេ តែគាត់ឲ្យនាងជួយការងារផ្ទះគាត់សិន។ ម៉្យាងទៀត ឪពុកម្ដាយខ្លះ សម្លឹងឃើញថាពេលបច្ចុប្បន្ននេះសិស្សមួយចំនួន ដែលបានបញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ ឬកម្រិតបរិញ្ញាបត្រ នៅតែមិនមានការងារធ្វើ។ ហេតុដូច្នេះហើយ ធ្វើឲ្យពួកគាត់មិនបានយកចិត្តទុកដាក់ ឬជួយជំរុញការសិក្សារបស់កូនគាត់ទេ។ នេះមិនខុសពីអ្វី ដែលលោក ម៉ាក ប្រេ និងសេង ប៊ុនលី បានលើកឡើងនៅក្នុង"សៀវភៅតុល្យការ"របស់គាត់ទេ ដែលថា៖"នៅពេលដែលគ្រួសារសិស្សពិចារណាថា តើគួបញ្ជូនកូនទៅសាលា ឬមិនបញ្ជូន មាតាបិតាបានធ្វើការវាយតម្លៃក្រៅផ្លូវការ ដើម្បីពិនិត្យមើលថា តើការចំណាយសម្រាប់បញ្ជូនកូនទៅសាលារៀនអាចផ្ដល់ផលប្រយោជន៍កម្រិតណា" (2005, p.83)។

បញ្ហាជីវភាព ជាមូលហេតុមួយដែលធ្វើឲ្យក្មេងគ្មានទាំងថវិកា និងពេលវេលាទៅរៀនគួ។ បញ្ហាជីវភាព តម្រូវឲ្យសិស្សដែលទៅ

រៀននៅសាលារដ្ឋមិនបានជាប់លាប់ ឬមិនបានទៅរៀនគួ ត្រូវជួយធ្វើការក្រុមគ្រួសារ ដើម្បីជួយសម្រួលបន្ទុករបស់គ្រួសារ។ ក្នុងនោះមានសិស្សខ្លះជួយធ្វើការងារស្រែចម្ការ ចាក់កន្ត្រកការងារផ្ទះ ដូចជាមើលផ្ទះ សំអាតផ្ទះ មើលប្អូនតូចៗ ឃ្វាលគោ ទៅកាប់អុសជាដើម។ ពិតមែនតែការជួយនេះមិនបានផ្តល់ជាលុយកាក់ដោយផ្ទាល់ដល់ក្មេងក៏ដោយ ក៏ការងារនេះ ជួយសម្រួលដល់បន្ទុកការងារនៅក្នុងគ្រួសារ ឬអាចធ្វើឲ្យឪពុកម្តាយមានពេលវេលា សម្រាប់ទៅធ្វើការងារក្រៅផ្ទះ ដើម្បីរកចំណូលសម្រាប់ជីវភាពរបស់គ្រួសារដែរ។ ជាឧទាហរណ៍ សិស្សម្នាក់ត្រូវជួយកិនម្សៅ និងទៅជួយកាប់អុសម្តាយរបស់នាង ក្រោយពេលទទួលទានអាហារថ្ងៃត្រង់រួច។ នាងនិយាយថា៖ "ហូបបាយហើយ គាត់កិនម្សៅ គាត់កិនម្សៅហើយ ដល់ពេលថ្ងៃត្រង់បន្តិច គាត់ទៅកាប់អុសទៅ ទៅកាប់ជាមួយគាត់"។រីឯសិស្សមួយចំនួនទៀតបានឆ្លៀតពេលក្រៅម៉ោងសិក្សារដ្ឋ ទៅធ្វើការងារផ្សេងៗនៅក្រៅផ្ទះ ដែលពួកគេអាចធ្វើបាន ដើម្បីរកប្រាក់ចំណូលដើម្បីសម្រាលបន្ទុកនៃការចំណាយរបស់គ្រួសារ ដូចដែលករណីសិស្សម្នាក់ដែលធ្វើការនៅកសិដ្ឋានសេះមួយកន្លែង ដែលមានភ្ញៀវទេសចរណ៍ទៅជិះសេះកម្សាន្ត បានប្រាប់ថា៖ "ខ្ញុំធ្វើការខាងជិះសេះជូនភ្ញៀវ ជូតoffice និងបន្ទប់ទឹក និងធ្វើការផ្សេងទៀត។"



## ការយល់ឃើញទៅលើសិស្សរៀនគួ និងមិនរៀនគួ

ការរៀនគួត្រូវបានយល់ឃើញថា មានសារៈសំខាន់ ក្នុងការជួយបង្កើនចំណេះដឹងរបស់សិស្សបន្ថែមលើការខ្វះខាតដែលបានរៀននៅសាលារដ្ឋ។ ប៉ុន្តែដោយសារបញ្ហាថ្លៃបង់គួ ទើបធ្វើឲ្យសិស្សមួយចំនួនមិនបានចូលរៀនគួ( បើទោះបីមានគ្រូខ្លះបានអនុញ្ញាតឲ្យសិស្សដែលពុំមានលទ្ធភាពបង់គួ ចូលរៀនគួដោយឥតគិតថ្លៃ ឬជំពាក់ក៏ដោយ ក៏ករណីនេះពុំសូវឃើញមានសិស្សគ្មានលទ្ធភាព ទៅរៀនគួច្រើនដែរ)។ ការដែលមិនបានទៅរៀនគួនេះឯង ធ្វើឲ្យមានការយល់ឃើញបែបផ្សេងៗគ្នាទៅសិស្សដែលរៀនគួ និងមិនរៀនគួ។

បើនិយាយពីផ្នែកសម្ភារវិញ យើងឃើញមានការទទួលស្គាល់ នូវភាពខុសគ្នារវាងគ្រួសារ ដែលបញ្ជូនកូនទៅរៀនគួ និងគ្រួសារដែលមិនបានបញ្ជូន។ គ្រួសារណា ដែលមានមធ្យោបាយធ្វើដំណើរទំនើប (ដូចជាម៉ូតូស៊េរី ០៥ ឡើង) មានផ្ទះថ្មប្រក់ក្បឿង មានដីធំឬលក់ឥវ៉ាន់នៅក្នុងភូមិនោះកូនរបស់គាត់ទំនងជាត្រូវបានបញ្ជូនទៅរៀនគួ។ រីឯគ្រួសារដែលទំនងជាមិនបានបញ្ជូនកូនទៅរៀនគួវិញនោះជាគ្រួសារដែលកូនរបស់គាត់មិនមានសម្លៀកបំពាក់ ឬឯកសណ្ឋានសម្រាប់ទៅសាលាគ្រប់គ្រាន់ គ្មានអាហារហូបចុកគ្រប់គ្រាន់ គ្មានប្រាក់ថែទាំសុខភាពរស់នៅក្នុងផ្ទះតូចគ្មានដីធ្វើកសិកម្ម និងមានសមាជិកគ្រួសារច្រើន។

នៅក្នុងការពិភាក្សាក្រុម ភាគច្រើនសិស្សដែលបានទៅរៀនគួត្រូវបានយល់ឃើញថាជា សិស្សល្អ ពូកែយកចិត្តទុកដាក់ឧស្សាហ៍ព្យាយាមរៀនសូត្រទាំងនៅផ្ទះ និងនៅសាលា។ នៅក្នុងថ្នាក់រៀន មានភាពក្លាហាន ហ៊ានសួរគ្រូនូវរាល់ចំណុចណាដែលគេមិនយល់ មានពេលវេលាគ្រប់គ្រាន់សម្រាប់ការសិក្សា ដែលខុសពីសិស្សដែលមិនបានរៀនគួ។ សិស្សមិនបានរៀនគួខ្លះត្រូវបានយល់ឃើញថាខ្ជិល ខ្លះមិនមានថវិកានិងពេលវេលាសម្រាប់ការសិក្សាមិនសូវមានភាពក្លាហាន សូម្បីតែក្នុងការសួរ ឬឆ្លើយសំណួរក្នុងថ្នាក់រៀន ក៏ពួកគេមិនដឹងថាត្រូវចាប់ផ្តើមពីចំណុចណាដែរ។ មានការយល់ឃើញថា ចំណេះដឹងជាចំណែកមួយដែលធ្វើឲ្យសិស្សរៀនគួមានភាពក្លាហាន។ ហេតុដូចច្នេះហើយទើបធ្វើឲ្យក្មេងដែលមិនបានរៀនគួមួយចំនួនមានអារម្មណ៍តូចចិត្តនឹងខ្លួនឯង ច្រណែនឬអស់សង្ឃឹមក្នុងការសិក្សារបស់ពួកគេ។ សិស្សម្នាក់ដែលមិនបានរៀនគួ បានលើកឡើងថា៖"នៅពេលគេ[សិស្សដែលរៀនគួ]រៀនគួទៅពេលគ្រូដាក់សំណួរ គេធ្វើរួចមុនរហូត ដល់ពេលដាច់ខែគេជាប់លេខ ១។"សិស្សម្នាក់ទៀតបាននិយាយថា៖ "ខ្ញុំមានអារម្មណ៍ថាច្រណែន និងអស់សង្ឃឹម" [ក្នុងការប្រលង]។ រីឯគ្រូបង្រៀនម្នាក់

បានមានប្រសាសន៍ថាសិស្សដែលមិនបាន រៀនគួ ប្រហែលជាអន់ចិត្តខ្លះ ដែលពួកគេមិន មានលុយទៅរៀនគួ ហើយប្រហែលជាគិតថា សិស្សដែលទៅរៀនគួប្រាកដជាចេះជាងខ្លួន។



## ប្រាក់ខែគ្រូបង្រៀន

ប្រាក់ខែជាបញ្ហាមួយដែលគ្រូបង្រៀនតែងតែត្អូញត្អែរថា ពុំមានលក្ខណៈគ្រប់គ្រាន់ដែលអាចធ្វើឲ្យគាត់រស់នៅបានសមរម្យប្រសិនបើគ្មានចំណូលពីប្រភពផ្សេងទៀត។ តាមទិន្នន័យនៅក្នុងឆ្នាំ ២០០៤ របស់ធនាគារពិភពលោកបានបង្ហាញថា គ្រូបង្រៀន ៦៨.៥ % មានមុខរបរទី ២ដូចជា ធ្វើស្រែចម្ការ ចិញ្ចឹមសត្វ លក់ដូរឥវ៉ាន់នៅផ្សារ និងរត់ម៉ូតូឌុបជាដើម (Benveniste, Marshall & Araujo, 2008, p.68)។ ចំណែកឯប្រភពចំណូលមួយទៀតគឺបានមកពីការបង្រៀនគួ។

ដោយសារប្រាក់ខែមិនអាចទប់ទល់នឹងជីវភាពរស់នៅបាន គ្រូបង្រៀនបានរកចំណូលបន្ថែមតាមរយៈការបង្រៀនគួ។ គ្រូបង្រៀនម្នាក់បានលើកឡើងថាៈ "វាពិបាកដែរស្រុកខ្មែរយើង បើនិយាយឲ្យចំទៅ រឿងលុយហ្នឹង ប្រាក់ខែវាទាប តិចពេក។ ដូច្នេះហើយ ការរៀនគួត្រូវតែជំរុញ វាត្រូវតែមានករណីនេះកើតឡើង។"ការបង្រៀនគួនេះ អាចជួយសម្រួលកម្រិតជីវភាពតិច ឬច្រើនអាស្រ័យទៅលើកម្រិតប្រាក់ចំណូលដែលទទួលបានពីការបង្រៀនគួនេះ។ នៅក្នុងការសិក្សានេះយើងដឹងថាសិស្សនៅទីក្រុង ទៅរៀនគួច្រើនជាងសិស្សនៅជនបទ និងថ្លៃរៀនគួ ក៏ថ្លៃជាងនៅជនបទដែរ។ ដូច្នេះ យើងអាចសន្មត់ថា គ្រូនៅទីក្រុងអាចរកប្រាក់ចំណូលតាមរយៈការបង្រៀនគួ បានច្រើនជាង គ្រូនៅជនបទ។

គ្រូបង្រៀននៅជនបទម្នាក់បានលើកឡើងថា ដោយសារបញ្ហាប្រាក់ខែ ទើបធ្វើឲ្យគ្រូបង្រៀនមិនបានយកចិត្តទុកដាក់លើការងារបង្រៀនរបស់គាត់ ដោយសារតែគាត់ផ្តោតសំខាន់លើជីវភាពគ្រួសាររបស់គាត់។គាត់មានប្រសាសន៍ថាអារម្មណ៍របស់គ្រូអត់មូលពេលបង្រៀនៈ "បើនិយាយរួមទៅ [គ្រូ] មក [សាលា] តែខ្លួន ព្រលឹងនៅផ្ទះ។"

## ការពិភាក្សា

ការរៀនគួ នៅក្នុងប្រទេសកម្ពុជា មានឥទ្ធិពលលើការរៀន និងបង្រៀននៅសាលារដ្ឋ។ ទី១ ទិន្នន័យនៅក្នុងការសិក្សានេះ បង្ហាញថាការរៀនគួនៅថ្នាក់ទី ៦ មានការកើនឡើងច្រើនជាងទិន្នន័យនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ដែលបង្ហាញដោយលោក ម៉ាក ប្រេ(Bray 1999)។ ទី២ ទិន្នន័យបង្ហាញថាសិស្សដែលរៀនគួនៅថ្នាក់ទី ៩ មានចំនួនច្រើនជាងសិស្សរៀនគួនៅថ្នាក់ទី ៦។ ចំណុចទាំងពីរនេះស្របតាមការរកឃើញអំពីកំណើននៃការរៀនគួនៅលើពិភពលោក ជាពិសេសនៅទ្វីបអាស៊ី

(Bray & Lykins, 2012)។ ទី ៣ ភាពស្រដៀងគ្នានៃការសិក្សានៅក្នុងថ្នាក់រដ្ឋ និងថ្នាក់រៀនគួភាគច្រើនបង្ហាញថាការសិក្សានៅថ្នាក់គួ ជាការបន្តការសិក្សាពីក្នុងថ្នាក់រដ្ឋ។នៅក្នុងថ្នាក់គួគ្រូអាចប្រើវិធីសាស្ត្រនៃការបង្រៀនដែលសម្របទៅតាមតម្រូវការរបស់សិស្សច្រើនជាងនៅក្នុងថ្នាក់រៀនរដ្ឋ។ ទី៤ យើងរកឃើញថា អ្នកដែលចូលរួមភាគច្រើន យល់ឃើញថាការរៀនគួ គឺដើម្បីបញ្ចប់កម្មវិធីសិក្សារដ្ឋនិងដើម្បីនឹងទទួលបានចំណេះដឹងល្អ ដែលនឹងធ្វើឲ្យអនាគតរបស់សិស្សមានភាពរុងរឿង។ ទី ៥ ការសិក្សាស្រាវជ្រាវនេះ បានរកឃើញនូវ គម្លាតសង្គមរវាងសិស្សដែលរៀនគួ និងមិនរៀនគួ។ ជាទូទៅ ការរៀនគួ គឺជាសេវាអប់រំសម្រាប់សិស្សមកពីគ្រួសារ ដែលជីវភាពធូរធា និងមធ្យមនៅក្នុងសង្គម។

នៅពេលយើងសួរគ្រូបង្រៀនថាតើធ្វើយ៉ាងម៉េច ដើម្បីឲ្យការអប់រំរបស់សិស្សបានល្អ គាត់បានផ្តល់យោបល់ថា ការសិក្សារបស់សិស្សទាក់ទងនឹងកត្តាបីយ៉ាង គឺ ការជួយជំរុញពីឪពុកម្តាយ ការយកចិត្តទុកដាក់ពីគ្រូបង្រៀន និងការហូបចុកគ្រប់គ្រាន់។ ទី ១ ការជួយជំរុញពីឪពុកម្តាយទាក់ទងនឹងភាពខុសគ្នារវាងគ្រួសាររបស់សិស្សរៀនគួនិងសិស្សមិនរៀនគួ (ដូចដែលបានរៀបរាប់ខាងលើ)។ បញ្ហាជីវភាព តម្រូវឲ្យឪពុកម្តាយធ្វើការសម្រេចចិត្តយ៉ាងលំបាក ថាតើគួបញ្ជូនកូនទៅរៀនគួ ឬមួយឲ្យកូនជួយធ្វើការងារផ្ទះដើម្បីការរស់នៅប្រចាំថ្ងៃ។ ទី ២ ការយកចិត្តទុកដាក់ពីគ្រូបង្រៀនបង្ហាញពីទំនាក់ទំនងរវាងសិស្ស និងគ្រូបង្រៀន។ ទំនាក់ទំនងនេះ អាចនឹងមានទំនោរទៅរកភាពមិនល្អ នៅពេលដែលការអប់រំត្រូវបានចាត់ទុកជាទំនិញពោលគឺខណៈដែលសិស្សខ្លះបានបង់ប្រាក់ទៅគ្រូបង្រៀនរបស់ខ្លួន សម្រាប់ការសិក្សាបន្ថែម នោះភាពលម្អៀងនៃការយកចិត្តទុកដាក់របស់គ្រូមួយចំនួនទៅលើសិស្សនៅក្នុងថ្នាក់រៀនរដ្ឋអាចនឹងកើតឡើង។ទី ៣ ការហូបចុកឲ្យបានគ្រប់គ្រាន់ ជាបញ្ហាសំខាន់ ដែលទាក់ទងនឹងការចំណាយនៅក្នុងគ្រួសារដែរ។ ប្រសិនបើការអប់រំ គឺជាការចំណាយដ៏ច្រើនបំផុតរបស់គ្រួសារ (Bray & Bunly, 2005; NEP 2007) នោះការរាវរកចិត្ត ក្នុងការបញ្ជូនកូនទៅរៀន ឬទិញអាហារហូបចុកឲ្យបានគ្រប់គ្រាន់ នឹងក្លាយជាទម្លាប់នៃការគិតប្រចាំថ្ងៃរបស់ឪពុកម្តាយ។ សិស្សខ្លះមើលឃើញថាការសិក្សា ឬការរៀនគួពុំបានផ្តល់អត្ថប្រយោជន៍អ្វីដល់ខ្លួនឡើយ ដូចគ្នានឹងការយល់ឃើញរបស់ឪពុកម្តាយសិស្សខ្លះ ដែលបានលើកឡើងខាងលើដែរ។ សិស្សរៀនគួម្នាក់បាននិយាយថាខ្លួនបានណែនាំមិត្តរួមថ្នាក់ម្នាក់របស់ខ្លួន

ដែលកំពុងលេងបាល់ទាត់ ឲ្យទៅរៀនគួ តែមិត្តភក្តិរបស់ខ្លួនបានឆ្លើយមកវិញថា "រៀនបានស៊ី?" ពិតមែនថា ពាក្យសម្តីនេះច្រើនប្រើជាការនិយាយលេង ប៉ុន្តែអ្នកប្រើសម្តីនេះអាចមើលឃើញថាការអប់រំត្រូវការចំណាយថវិកាច្រើន និងរយៈពេលយូរហើយមិនប្រាកដថា ការអប់រំអាចផ្តល់ផលប្រយោជន៍ដល់ខ្លួន ឬអត់នោះទេ។

អ្វីដែលបន្ថែមលើកត្តាទាំងបីខាងលើគឺប្រព័ន្ធអប់រំពុំទាន់មានការឧបត្ថម្ភគ្រប់គ្រាន់[2] និងថ្នាក់រៀនមានគ្នាច្រើនពេក ដែលបានប្តូរការផ្តល់ការអប់រំដែលមានគុណភាពពីប្រព័ន្ធអប់រំរដ្ឋ ទៅក្នុងប្រព័ន្ធរៀនគួ ដែលត្រូវបង់លុយ ហើយជាលទ្ធផលប្រព័ន្ធរៀនគួធ្វើឲ្យមានការយល់ឃើញខុសគ្នា (ដោយសិស្សខ្លួនឯង គ្រូបង្រៀន ឪពុកម្តាយ) ចំពោះសិស្ស ដូចជា ឧស្សាហ៍/ខ្ជិល ក្លាហាន/ភ័យខ្លាច ឬឆ្លាត/ល្ងង់ អាស្រ័យលើលទ្ធភាពរបស់ពួកគេក្នុងការចូលរៀនគួនោះឯង។

រាជរដ្ឋាភិបាល និងអ្នកស្រាវជ្រាវមួយចំនួនក៏បានដឹងអំពីការចំណាយក្រៅផ្លូវការរបស់គ្រួសារ ទៅលើការអប់រំរបស់កូនៗគាត់ដែរ។ ហេតុដូចច្នេះ រាជរដ្ឋាបាលបានព្យាយាមដោះស្រាយបញ្ហានេះ ដោយមានចេញសេចក្តីប្រកាសលេខ ៥១៣ ពីក្រសួងអប់រំ យុវជន និងកីឡា នៅឆ្នាំ២០០៥ ស្តីពីលប់បំបាត់ការចំណាយក្រៅផ្លូវការរបស់សិស្សនៅបឋមសិក្សា និងមធ្យមសិក្សា និងនៅឆ្នាំ ២០០៨ បានចេញអនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ដែលក្នុងនោះបានហាមប្រាមការយកលុយក្រៅផ្លូវការពីសិស្សនិងការធ្វើអាជីវកម្មក្នុងបរិវេណសាលា។ ឧទាហរណ៍៖ មាត្រា ១៣ នៃអនុក្រឹត្យនេះបានចែងថា៖ "គ្រូបង្រៀនមិនត្រូវរៃអង្គាសប្រាក់ ឬ ប្រមូលប្រាក់ក្រៅផ្លូវការ ឬ ធ្វើអាជីវកម្មនានាក្នុងថ្នាក់រៀនឡើយ។ គ្រូបង្រៀនត្រូវជៀសវាងការប្រកបមុខរបរផ្សេងក្នុងបរិវេណគ្រឹះស្ថានសិក្សា។"



[2] កម្ពុជាចំណាយថវិកា ២.៣%នៃផលិតផលក្នុងស្រុកសរុប(GDP) លើវិស័យអប់រំ ដែលចំនួននេះស្ថិតនៅក្នុងចំណោមប្រទេសដែលចំណាយតិចបំផុតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងនៅក្រោមការចំណាយជាមធ្យមរបស់ពិភពលោកដែលមានចំនួន ៤.៨%(European Commission 2012)

# សន្និដ្ឋាន

ប្រព័ន្ធអប់រំនៅប្រទេសកម្ពុជា គឺជាការលាយបញ្ចូលគ្នារវាងការសិក្សានៅសាលារដ្ឋ និងការរៀនគួ។ ដោយសារការរៀនគួជាការបន្តការសិក្សាពីសាលារដ្ឋ យើងអាចហៅការអប់រំបែបនេះថាជា ប្រព័ន្ធអប់រំកូនកាត់រដ្ឋ-ឯកជន។ ដើម្បីទទួលបានការអប់រំគ្រប់គ្រាន់ សិស្សត្រូវចំណាយថវិកា លើការសិក្សាក្រៅម៉ោងបន្ថែម។ បន្ទុកនៃការចំណាយនេះ ត្រូវធ្លាក់ទៅលើគ្រួសារសិស្ស ដែលត្រូវកំណត់បរិមាណ និងប្រភេទនៃការអប់រំដែលកូនរបស់គាត់ត្រូវការ។ របាយការណ៍នេះផ្តោតសំខាន់ទៅលើតួនាទីនៃការរៀនគួ នៅក្នុងប្រព័ន្ធអប់រំរដ្ឋដោយយើងធ្វើការសិក្សានិងប្រៀបធៀបវិធីសាស្ត្របង្រៀន ដែលគ្រូបានប្រើ នៅក្នុងថ្នាក់រដ្ឋ និងថ្នាក់រៀគួ។ យើងក៏ធ្វើការសិក្សាអំពីផលប៉ះពាល់ផ្នែកសង្គម ដែលបណ្តាលមកពីប្រព័ន្ធរៀនគួផងដែរ។

ការទទួលសេវាអប់រំជាលក្ខណៈបែបនេះ ធ្វើឲ្យទិដ្ឋភាពនៃការអប់រំមានលក្ខណៈមិនស្មើគ្នា ដែលកម្រិតនៃគុណភាពអប់រំ ត្រូវអាស្រ័យលើការជ្រើសរើសរបស់ឪពុកម្តាយ ដោយសារតែការកើនឡើងនៃការពឹងផ្អែកលើសេវាឯកជន។ ប្រព័ន្ធអប់រំកូនកាត់ រដ្ឋ-ឯកជននេះធ្វើឲ្យសិស្សក្រីក្រ មិនអាចទទួលបានការអប់រំដូចសិស្សដែលមានជីវភាពធូរធាទេដែលនេះ

ធ្វើឲ្យមានគម្លាតសង្គម។ ហេតុដូចច្នេះ ដើម្បីកាត់បន្ថយគម្លាតនេះ ជាជំហានដំបូងយើងត្រូវទទួលស្គាល់គម្លាតសង្គម ដែលបង្កើតឡើងដោយការរៀនគួនេះនិងចាប់ផ្តើមនិយាយអំពីប្រព័ន្ធអប់រំ ដោយលើកយកទាំងការអប់រំរដ្ឋនិងរៀនគួ ដែលយើងមើលឃើញទាំងអស់គ្នា។

ដើម្បីចាប់ផ្តើមការនិយាយនេះបានយើងត្រូវការធ្វើការសិក្សាស្រាវជ្រាវបន្ថែមទៀតលើកម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀន ដែលគ្រូប្រើទាំងនៅក្នុងការសាលារដ្ឋនិងនៅថ្នាក់រៀនគួ និងសិក្សាអំពីផលប៉ះពាល់រយៈពេលវែងលើសង្គម ដែលបណ្តាលមកពីការរៀនគួ។

## ឯកសារយោង:


Aggarwal, Y. (1998). *Primary education in Delhi: How much do the children learn?* New Delhi: National Institute of Educational Planning and Administration.

Benveniste, L., Marshall, J., & Araujo, M. C. (2008). *Teaching in Cambodia.* Washington, DC: World Bank.

Bray, M. (1999). *The private costs of public schooling: Household and community financing of primary education in Cambodia.* Paris: UNESCO International Institute for Educational Planning (IIEP).

Bray, M., and Bunly, S. (2005) *Balancing the books: Household financing of basic education in Cambodia.* Hong Kong: Comparative Education Research Centre, The University of Hong Kong.

Bray, M. (2009). *Confronting the shadow education system: What government policies for what private tutoring?* Paris: UNESCO International Institute for Educational Planning (IIEP).

Bray, M. (2011). *The challenge of shadow education: Private tutoring and its implications for policy makers in the European Union.* Brussels: European Commission.

Bray, M. and Lykins, C. (in press). *Shadow education: Private supplementary tutoring and its implications for policy makers in Asia.* To be published by the Asian Development Bank.

Fergany, N. (1994). *Survey of access to primary education and acquisition of basic literacy skills in three governorates in Egypt.* Cairo: UNICEF; Almishkat Centre for Research and Training.

Hallak, J. and Poisson, M. (2007). *Corrupt schools, corrupt universities: What can be done?* Paris: UNESCO International Institute for Educational Planning (IIEP).

Hussein, M.G.A. (1987). Private tutoring: A hidden educational problem. *Education studies in mathematics,* 18(1), 91-96.

Nanayakkara, G.L.S. and Ranaweera, M. (1994).“Impact of private tuition and the educational challenges of the 21st century.” In: *Economic review* [The People’s Bank, Colombo], 20(2,3), 11-14, 17.

NEP (2007).*The Impact of Informal School Fees on Family Expenditures*. NGO Education Partnership, Education Operational Research. Retrieved June 1, 2011, from http://www.nepcambodia.org/pdffiles/NEP_Informal%20School%20Fee%20Report07.pdf

Nzomo, J., Kariuki, M., Guantai, L. (2001).*The quality of primary education: Some policy suggestions based on a survey of schools — Kenya*. Paris: UNESCO International Institute for Educational Planning (SACMEQ policy research report No. 6).

MoEYS [Ministry of Education, Youth & Sport] (2005).*Prakas #513 on abolishment of informal payments from students at public primary and secondary school.*Phnom Penh, Kingdom of Cambodia

Royal Government of Cambodia (2008).*Sub-decree on teacher professional ethic*. Phnom Penh, Kingdom of Cambodia



Copyright © 2012 by This Life Cambodia.

អង្គការ ជីវិតនៅកម្ពុជា
THIS LIFE
CAMBODIA

www.thislifecambodia.org